# បណ្ណសន្យារ៉ាប់រង
# GC គាំពារនារី

(តទៅនេះហៅថា “បណ្ណសន្យារ៉ាប់រងផលិតផលមូលដ្ឋាន”)

## I. និយមន័យ

**១. “បណ្ណសន្យារ៉ាប់រងផលិតផលមូលដ្ឋាន”** សំដៅទៅលើខ និងលក្ខខណ្ឌដែលពាក់ព័ន្ធនឹងអត្ថប្រយោជន៍ធានារ៉ាប់រងមូលដ្ឋាន ហើយត្រូវរាប់បញ្ចូលកិច្ចព្រមព្រៀង និង/ឬ កិច្ចសន្យាបន្ថែមទាំងអស់ លើកលែងតែមានការកំណត់ជាក់លាក់ថាកិច្ចព្រមព្រៀង និង/ឬ កិច្ចសន្យាបន្ថែមនោះមិនត្រូវបានចាត់បញ្ចូលជាផ្នែកនៃបណ្ណសន្យារ៉ាប់រងនេះ។

**២. “អ្នកទទួលផល”** សំដៅដល់តតិយជននៃកិច្ចសន្យាធានារ៉ាប់រងអាយុជីវិត ដែលនឹងទទួលបានអត្ថប្រយោជន៍ស្របច្បាប់ពីបណ្ណសន្យារ៉ាប់រងនេះ។

**៣. “ច្បាប់នៃប្រទេសកម្ពុជា”** សំដៅដល់ច្បាប់ដែលមាន និងបទប្បញ្ញត្តិណាមួយ ឬទាំងអស់ដែលត្រូវបានដាក់ឱ្យអនុវត្តនៅប្រទេសកម្ពុជានិង/ឬ រាល់វិសោធនកម្មដែលពាក់ព័ន្ធ។

**៤. “ការសម្រាលកូន”** សំដៅដល់ដំណើរការនៃការសម្រាលកូនក្នុងការមានគភ៌មួយលើកបានកូនម្នាក់ ឬកូនភ្លោះ ដែលអ្នកត្រូវបានធានារ៉ាប់រងគឺជាម្ដាយបង្កើត។

**៥. “ការឡើងភ្នំ”** សំដៅទៅលើសកម្មភាពនៃការឡើងភ្នំថ្មចំាងថ្ម ជញ្ជាំងក្រៅអាគារ ច្រាំងថ្មចោទដែលមនុស្សបង្កើត ជ្រោះទឹកកក និងភ្នំទឹកកក។

**៦. “រយៈពេលសម្រេចចិត្ត”** សំដៅទៅលើរយៈពេល ២១ (ម្ភៃមួយ) ថ្ងៃគិតចាប់ពីថ្ងៃដែលអ្នកបានទទួលបណ្ណសន្យារ៉ាប់រង។

**៧. “កិច្ចសន្យាធានារ៉ាប់រង”** សំដៅដល់កិច្ចសន្យាធានារ៉ាប់រងអាយុជីវិត ដែលធ្វើឡើងដោយ និងរវាងក្រុមហ៊ុន និងអ្នកត្រូវបានធានារ៉ាប់រង/ម្ចាស់បណ្ណសន្យារ៉ាប់រង។

**៨. “អាការៈជំងឺធ្ងន់ធ្ងរ”** គឺជាពេលដែលអ្នកត្រូវបានធានារ៉ាប់រងបានធ្វើរោគវិនិច្ឆ័យរកឃើញថាទទួលរងគ្រោះពីជំងឺធ្ងន់ធ្ងរណាមួយ ដូចដែលមានកំណត់នៅក្នុងតារាងជំងឺធ្ងន់ធ្ងរ។

**៩. “ចំណាត់ថ្នាក់ជំងឺធ្ងន់ធ្ងរ”** មានន័យថាជាចំណាត់ថ្នាក់នៃអាការៈជំងឺធ្ងន់ធ្ងរដូចមានកំណត់ក្នុងតារាងជំងឺធ្ងន់ធ្ងរ។

**១០. “ការធ្វើរោគវិនិច្ឆ័យ”** មានន័យថាការធ្វើរោគវិនិច្ឆ័យជាក់លាក់ណាមួយដោយគ្រូពេទ្យ ដោយផ្អែកទៅលើភស្តុតាងជាក់លាក់នោះ ដូចបានសំដៅដល់និយមន័យនៃអាការៈជំងឺធ្ងន់ធ្ងរជាក់លាក់ណាមួយ ឬនៅពេលអវត្តមានភស្តុតាងជាក់លាក់នោះ ដោយផ្អែកលើភស្តុតាងនៃវិទ្យុសាស្ត្រ សញ្ញាណគ្លីនិក ជាលិកាសាស្ត្រ ឬរបាយការណ៍មន្ទីរពិសោធន៍ដែលអាចទទួលស្គាល់បានដោយយើងខ្ញុំ។ ការធ្វើរោគវិនិច្ឆ័យនេះ ត្រូវតែទទួលបានការគាំទ្រដោយគ្រូពេទ្យដែលបានចាត់តាំងដោយយើងខ្ញុំ ដែលគាត់អាចសម្លាងគំនិតរបស់គាត់លើភស្តុតាងវេជ្ជសាស្ត្រដែលបានដាក់ជូនដោយអ្នកត្រូវបានធានារ៉ាប់រង និង/ឬ ភស្តុតាងបន្ថែមណាមួយដែលគ្រូពេទ្យអាចនឹងត្រូវការ។

ក្នុងករណីដែលមានជម្លោះ ឬភាពមិនយល់ស្របគ្នាពាក់ព័ន្ធនឹងភាពសមស្រប ឬភាពត្រឹមត្រូវនៃការធ្វើរោគវិនិច្ឆ័យនេះ យើងខ្ញុំត្រូវមានសិទ្ធិទាមទារឲ្យមានការពិនិត្យលើអ្នកត្រូវបានធានារ៉ាប់រង ឬលើភស្តុតាងដែលត្រូវបានប្រើប្រាស់រហូតដល់មានការធ្វើរោគវិនិច្ឆ័យនេះ ដោយអ្នកជំនាញឯករាជ្យក្នុងវិស័យសុខាភិបាលដែលពាក់ព័ន្ធ ហើយដែលត្រូវបានជ្រើសរើសដោយយើងខ្ញុំ ហើយគំនិតយោបល់របស់អ្នកជំនាញនោះទៅលើការធ្វើរោគវិនិច្ឆ័យនេះត្រូវមានអនុភាពភ្ជាប់កាតព្វកិច្ចលើទាំងអ្នកត្រូវបានធានារ៉ាប់រង និងយើងខ្ញុំ។

**១១. “ការជ្រមុជទឹក”** សំដៅដល់សកម្មភាពជ្រមុជទឹកនៅក្នុងទន្លេ បឹង សមុទ្រ អាងស្តុកទឹក ព្រែកជីក និងតំបន់ផ្ទៃទឹកផ្សេងទៀតដោយប្រើប្រាស់នូវឧបករណ៍ដកដង្ហើមជាជំនួយ។

**១២. “ជំងឺធ្ងន់ធ្ងរកម្រិតដំបូង”** មានន័យថាជាអាការៈជំងឺធ្ងន់ធ្ងរដែលមានស្ថានភាព ដូចបានកំណត់ក្នុងតារាងជំងឺធ្ងន់ធ្ងរ។

**១៣. “កាលបរិច្ឆេទចាប់ផ្តើមសុពលភាព”** ឬ **“កាលបរិច្ឆេទចាប់ផ្តើម”** គឺជាកាលបរិច្ឆេទដែលការធានារ៉ាប់រងស្របតាមបណ្ណសន្យារ៉ាប់រងផលិតផលមូលដ្ឋាននេះ ឬអត្ថប្រយោជន៍ធានារ៉ាប់រងបន្ថែមចូលជាធរមាន។ កាលបរិច្ឆេទចាប់ផ្តើមសុពលភាព ត្រូវបានបង្ហាញនៅលើវិញ្ញាបនបត្រធានារ៉ាប់រង ហើយកាលបរិច្ឆេទចាប់ផ្តើម គឺជាកាលបរិច្ឆេទនៃការចេញកិច្ចព្រមព្រៀង និង/ឬ កិច្ចសន្យាបន្ថែមនានា ដែលមានបង្ហាញក្នុងកិច្ចសន្យាបន្ថែមនីមួយៗនៅរាល់ពេលដែលខ និងលក្ខខណ្ឌដើមរបស់បណ្ណសន្យារ៉ាប់រងនេះត្រូវបានផ្លាស់ប្តូរជាបន្តបន្ទាប់។ កាលបរិច្ឆេទចាប់ផ្តើមក៏ជាកាលបរិច្ឆេទដែលទទួលបានការអនុញ្ញាតលើការបន្តសុពលភាពឡើងវិញនូវបណ្ណសន្យារ៉ាប់រងផលិតផលមូលដ្ឋាន និង/ឬអត្ថប្រយោជន៍ធានារ៉ាប់រងបន្ថែមក្នុងករណីដែលមានការបន្តសុពលភាពបណ្ណសន្យារ៉ាប់រងឡើងវិញ។

១៤. **“កាលបរិច្ឆេទផុតកំណត់”** សម្រាប់កិច្ចសន្យាធានារ៉ាប់រងបន្ថែម មានន័យថាជាកាលបរិច្ឆេទដែលកិច្ចសន្យាធានារ៉ាប់រងត្រូវផុតកំណត់ ដូចមានបង្ហាញក្នុងតារាងនៃអត្ថប្រយោជន៍ និងបុព្វលាភធានារ៉ាប់រងដែលបានចែងនៅក្នុងវិញ្ញាបនបត្រធានារ៉ាប់រង។

១៥. **“អត្ថប្រយោជន៍បង្កក់ខែកូន”** សំដៅដល់អត្ថប្រយោជន៍ដែលអាចទទួលបាននៅពេលដែលអ្នកត្រូវបានធានារ៉ាប់រងនៅរស់រានមានជីវិត និងទារកទារិកាមានអាយុបាន ៣០ (សាមសិប) ថ្ងៃ គិតនៅថ្ងៃដែលដាក់ទាមទារអត្ថប្រយោជន៍នេះ និងផ្អែកលើភស្តុតាងដែលត្រូវភ្ជាប់មកជាមួយរួមមាន សំបុត្រកំណើត ឬឯកសារមានតម្លៃស្មើ និងសៀវភៅតាមដានសុខភាពកុមារ ឬរបាយការណ៍វេជ្ជសាស្ត្រដែលមានតម្លៃស្មើផ្សេងៗ។

១៦. **“រយៈពេលអនុគ្រោះ”** មានន័យថារយៈពេល ៣០ (សាមសិប) ថ្ងៃគិតចាប់ពីកាលបរិច្ឆេទដល់កាលកំណត់ត្រូវបង់បុព្វលាភធានារ៉ាប់រង ដែលរយៈពេលនេះនឹងត្រូវបានអនុញ្ញាតសម្រាប់ការបង់បុព្វលាភធានារ៉ាប់រងបន្តបន្ទាប់។ បណ្ណសន្យារ៉ាប់រងនេះនឹងត្រូវបន្តមានសុពលភាពក្នុងអំឡុងពេលនៃរយៈពេលអនុគ្រោះនេះ។ ប្រសិនបើមានបុព្វលាភធានារ៉ាប់រងណាមួយមិនទាន់បានបង់នៅពេលផុតរយៈពេលអនុគ្រោះ កិច្ចសន្យាធានារ៉ាប់រងនេះ នឹងត្រូវផ្អាកសុពលភាព គិតចាប់ពីថ្ងៃបន្ទាប់នៃកាលបរិច្ឆេទផុតកំណត់នៃរយៈពេលអនុគ្រោះ។ បន្ទាប់មក កិច្ចសន្យាធានារ៉ាប់រងនេះនឹងត្រូវចាត់ទុកថាផ្អាកសុពលភាព និងមិនមានតម្លៃបន្តទៀតឡើយ លុះត្រាតែមានការស្នើសុំបន្តសុពលភាពបណ្ណសន្យារ៉ាប់រងឡើងវិញ តាមលក្ខខណ្ឌតម្រូវរបស់យើងខ្ញុំ។

១៧. **“អ្នកត្រូវបានធានារ៉ាប់រង”** សំដៅដល់ម្ចាស់បណ្ណសន្យារ៉ាប់រង និង/ឬ បុគ្គលដែលឈ្មោះ និងព័ត៌មានផ្ទាល់ខ្លួនត្រូវបានបង្ហាញលើវិញ្ញាបនបត្រធានារ៉ាប់រង។

១៨. **“ជំងឺធ្ងន់ធ្ងរកម្រិតធ្ងន់”** មានន័យថាជាអាការៈជំងឺធ្ងន់ធ្ងរដែលមានស្ថានភាព ដូចបានកំណត់ក្នុងតារាងជំងឺធ្ងន់ធ្ងរ។

១៩. **“កាលបរិច្ឆេទដល់កាលកំណត់”** មានន័យថាកាលបរិច្ឆេទដែលបណ្ណសន្យារ៉ាប់រងផលិតផលមូលដ្ឋាននេះដល់កាលកំណត់ ដូចដែលមានបង្ហាញនៅក្នុងវិញ្ញាបនបត្រធានារ៉ាប់រង។

២០. **“ម្ចាស់បណ្ណសន្យារ៉ាប់រង ម្ចាស់បណ្ណ ឬអ្នកបង់ប្រាក់”** សំដៅដល់បុគ្គល ដែលមានសិទ្ធិស្របច្បាប់លើបណ្ណសន្យារ៉ាប់រងនេះ។

២១. **“អចិន្ត្រៃយ៍”** មានន័យថាការណ៍ដែលរំពឹងថាអាចស្ថិតនៅពេញមួយជីវិតរបស់អ្នកត្រូវបានធានារ៉ាប់រង។

២២. **“គ្រូពេទ្យ”** មានន័យថាអ្នកប្រកបវិជ្ជាជីវៈវេជ្ជសាស្ត្រដែលបានចុះបញ្ជីត្រឹមត្រូវ មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងត្រូវបានផ្តល់អាជ្ញាបណ្ណក្នុងការប្រកបវិជ្ជាជីវៈពេទ្យតាមបែបបស្ចិមប្រទេស និងអ្នកដែល

ប្រកបវិជ្ជាជីវៈក្នុងទំហំវិសាលភាពនៃអាជ្ញាបណ្ណដែលបានផ្តល់ឲ្យ និងឆ្លងកាត់ការបណ្តុះបណ្តាលក្នុងតំបន់ភូមិសាស្ត្រជាក់លាក់មួយ ប៉ុន្តែលើកលែងចំពោះគ្រូពេទ្យ ឬគ្រូពេទ្យវះកាត់ដែលជាអ្នកត្រូវបានធានារ៉ាប់រងខ្លួនឯងផ្ទាល់។

**២៣. "បណ្ណសន្យារ៉ាប់រង"** សំដៅដល់បណ្ណសន្យារ៉ាប់រងផលិតផលមូលដ្ឋាន និងកិច្ចសន្យាធានារ៉ាប់រងបន្ថែមផ្សេងៗដែលអាចភ្ជាប់មកជាមួយបណ្ណសន្យារ៉ាប់រង។

**២៤. "ខួបនៃបណ្ណសន្យារ៉ាប់រង"** សំដៅដល់កាលបរិច្ឆេទដដែលៗជារៀងរាល់ឆ្នាំ ដូចនឹងកាលបរិច្ឆេទនៃបណ្ណសន្យារ៉ាប់រង។

**២៥. "បំណុលបណ្ណសន្យារ៉ាប់រង"** គឺជាចំនួនទឹកប្រាក់សរុបដែលអ្នកជំពាក់យើងខ្ញុំស្របតាមបណ្ណសន្យារ៉ាប់រងនេះ រួមទាំងប្រាក់ពិន័យដែលកើតមានឡើង។

**២៦. "កាលបរិច្ឆេទនៃបណ្ណសន្យារ៉ាប់រង"** គឺជាកាលបរិច្ឆេទចូលជាធរមាននៃបណ្ណសន្យារ៉ាប់រង ដូចមានបង្ហាញក្នុងវិញ្ញាបនបត្រធានារ៉ាប់រងជាក្រុម។ វាជាកាលបរិច្ឆេទដែលខួបនៃបណ្ណសន្យារ៉ាប់រង ឆ្នាំនៃបណ្ណសន្យារ៉ាប់រង ខែនៃបណ្ណសន្យារ៉ាប់រង និងកាលបរិច្ឆេទដល់កំណត់បង់បុព្វលាភធានារ៉ាប់រង ត្រូវបានកំណត់។

**២៧. "ឆ្នាំនៃបណ្ណសន្យារ៉ាប់រង"** សំដៅទៅរយៈពេល ១២ (ដប់ពីរ) ខែចន្លោះខួបនៃបណ្ណសន្យារ៉ាប់រងចំនួន២ (ពីរ) ។

**២៨. "បុព្វលាភធានារ៉ាប់រង"** សំដៅទៅលើចំនួនទឹកប្រាក់ដែលអ្នកត្រូវបង់មកឲ្យក្រុមហ៊ុនតាមការកំណត់របស់ក្រុមហ៊ុននៅក្នុងបណ្ណសន្យារ៉ាប់រងនេះ។

**២៩. "កាលបរិច្ឆេទឈប់បង់បុព្វលាភធានារ៉ាប់រង"** សំដៅទៅលើកាលបរិច្ឆេទនៅពេលដែលម្ចាស់បណ្ណសន្យារ៉ាប់រងឈប់បង់បុព្វលាភធានារ៉ាប់រងក្រោមបណ្ណសន្យារ៉ាប់រងនេះទៅកាន់ក្រុមហ៊ុន ហើយកាលបរិច្ឆេទនេះមានបង្ហាញនៅក្នុងវិញ្ញាបនបត្រធានារ៉ាប់រង។

**៣០. "ចំនួនទឹកប្រាក់ត្រូវបានធានារ៉ាប់រង"** មានន័យថាជាចំនួនទឹកប្រាក់នៃការធានារ៉ាប់រងដែលបានកំណត់នៅពេលចេញបណ្ណសន្យារ៉ាប់រង និងដែលត្រូវបានបង្ហាញនៅក្នុងវិញ្ញាបនបត្រធានារ៉ាប់រង។ ប្រសិនបើចំនួនទឹកប្រាក់ត្រូវបានធានារ៉ាប់រងត្រូវបានកែប្រែជាបន្តបន្ទាប់ទៅតាមខ និងលក្ខខណ្ឌនៃបណ្ណសន្យារ៉ាប់រង ចំនួនទឹកប្រាក់ក្រោយការកែប្រែនេះនឹងក្លាយជាចំនួនទឹកប្រាក់ត្រូវបានធានារ៉ាប់រង។

**៣១. "អត្ថប្រយោជន៍ធានារ៉ាប់រងបន្ថែម"** សំដៅទៅលើអត្ថប្រយោជន៍ ឬការធានារ៉ាប់រងបន្ថែមទៅលើបណ្ណសន្យារ៉ាប់រងផលិតផលមូលដ្ឋាននេះ។ វាត្រូវបានដាក់ភ្ជាប់ជាមួយនឹងបណ្ណសន្យារ៉ាប់រងនេះ ប្រសិនបើ

ឈ្មោះផលិតផល ឬកូដ និងលេខសម្គាល់ទម្រង់ឯកសារ មានបង្ហាញនៅលើវិញ្ញាបនបត្រធានារ៉ាប់រង ឬក្រោយមកត្រូវបានដាក់បន្ថែមដោយកិច្ចព្រមព្រៀង និង/ឬ កិច្ចសន្យាបន្ថែមផ្សេងៗ។

៣២. “**ពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍**” ឬ “**ពិការភាព**” មានន័យថាអ្នកត្រូវបានធានារ៉ាប់រងរងគ្រោះដោយការបាត់បង់ទាំងស្រុង និងដែលមិនអាចជាសះស្បើយឡើងវិញបានជាអចិន្ត្រៃយ៍នូវ÷

- ដៃទាំងពីរ ឬ
- ជើងទាំងពីរ ឬ
- ដៃម្ខាង និងជើងម្ខាង ឬ
- ភ្នែកទាំងពីរ ឬ
- ភ្នែកម្ខាង និងដៃម្ខាង ឬ
- ភ្នែកម្ខាង និងជើងម្ខាង។

តាមរយៈនិយមន័យនេះ ការបាត់បង់ទាំងស្រុង និងមិនអាចជាសះស្បើយឡើងវិញបានជាអចិន្ត្រៃយ៍នូវ (ក) ភ្នែកម្ខាង ឬទាំងពីរ សំដៅដល់ការបាត់បង់គ្រាប់ភ្នែក ឬពិការភ្នែកទាំងស្រុង (ខ) ដៃម្ខាង ឬទាំងពីរ សំដៅដល់ការបាត់បង់ចាប់ពីផ្នែកខាងលើនៃកដៃឡើងទៅ និង (គ) ជើងម្ខាង ឬទាំងពីរ សំដៅដល់ការបាត់បង់ចាប់ពីផ្នែកខាងលើនៃកជើងឡើងទៅ។

ក្នុងករណីបាត់បង់ដៃ ឬជើង ឬភ្នែកទាំងស្រុង លិខិតបញ្ជាក់អំពីការបាត់បង់នេះអាចត្រូវបានធ្វើឡើងនៅពេលណាក៏បានក្នុងអំឡុងរយៈពេលនៃការធានារ៉ាប់រង និងនាពេលដែលបណ្ណសន្យារ៉ាប់រងនៅមានសុពលភាព។ តាមរយៈនិយមន័យនេះ ការបាត់បង់ទាំងស្រុង និងមិនអាចជាសះស្បើយឡើងវិញបានជាអចិន្ត្រៃយ៍នូវដៃម្ខាង ឬទាំងពីរ ឬជើងម្ខាង ឬទាំងពីរ ក៏មានន័យថាជាការបាត់បង់នូវមុខងារប្រើប្រាស់របស់ដៃម្ខាង ឬទាំងពីរ ឬជើងម្ខាង ឬទាំងពីរនោះដែរ ប្រសិនបើមានការបញ្ជាក់ត្រឹមត្រូវពីមន្ទីរពេទ្យ ដែលបានចុះបញ្ជីយ៉ាងហោចណាស់ត្រឹមថ្នាក់ខេត្តថាការបាត់បង់នោះកើតឡើងបន្ទាប់ពីថ្ងៃកំណើតឆ្នាំទី ១៨ (ដប់ប្រាំបី) របស់អ្នកត្រូវបានធានារ៉ាប់រង ហើយដែលស្ថានភាពពិការនេះមានរយៈពេលយ៉ាងហោចណាស់ ៦ (ប្រាំមួយ) ខែ។

៣៣. “**រយៈពេលរង់ចាំ**” សំដៅទៅលើរយៈពេលចាប់ពីកាលបរិច្ឆេទចាប់ផ្តើមសុពលភាព ឬកាលបរិច្ឆេទនៃការបន្តសុពលភាពបណ្ណសន្យារ៉ាប់រងឡើងវិញ ដោយយកកាលបរិច្ឆេទចុងក្រោយគេ។ រយៈពេលរង់ចាំសម្រាប់ជំងឺធ្ងន់ធ្ងរកម្រិតដំបូង មានរយៈពេល ១២០ (មួយរយម្ភៃ) ថ្ងៃ រយៈពេលរង់ចាំសម្រាប់ជំងឺធ្ងន់ធ្ងរកម្រិតធ្ងន់មានរយៈពេល ៩០ (កៅសិប) ថ្ងៃ និងរយៈពេលរង់ចាំមួយឆ្នាំសម្រាប់ការសម្រាលកូន។

៣៤. "**ពួកយើងខ្ញុំ**" "**យើងខ្ញុំ**" "**របស់យើងខ្ញុំ**" ឬ"**ក្រុមហ៊ុន**" សំដៅដល់ក្រុមហ៊ុន ជីស៊ី ឡាយហ្វ៍ អ៊ិនសួរេន ម.ក។

៣៥. "**អ្នក**" ឬ"**របស់អ្នក**" មានន័យថាម្ចាស់បណ្ណសន្យារ៉ាប់រងនេះ ដូចមានបង្ហាញក្នុងវិញ្ញាបនបត្រធានារ៉ាប់រងនេះ។

ពេលណាដែលបរិបទតម្រូវ វាក្យស័ព្ទមានភេទប្រុស ត្រូវអនុវត្តចំពោះវាក្យស័ព្ទភេទស្រីផងដែរ ហើយវាក្យស័ព្ទជាឯកវចនៈ ត្រូវរាប់បញ្ចូលទាំងវាក្យស័ព្ទជាពហុវចនៈដែរ។

## II. កម្មវត្ថុនៃការធានា

អាយុជីវិតរបស់អ្នកត្រូវបានធានារ៉ាប់រង។

## III. វិសាលភាពនៃការធានា

បណ្ណសន្យារ៉ាប់រងនេះផ្តល់នូវ÷

១. ការការពារលើមរណភាព និងពិការភាពក្នុងកំឡុងពេលដែលបណ្ណសន្យារ៉ាប់រងនេះមានសុពលភាព។

២. អត្ថប្រយោជន៍នៅរស់រានមានជីវិត និងអត្ថប្រយោជន៍បង្គក់ខែកូន ដែលនឹងត្រូវផ្តល់ជូនតាមកាលបរិច្ឆេទ និងលក្ខខណ្ឌដែលបានកំណត់។

៣. ការការពារលើជំងឺធ្ងន់ធ្ងរកម្រិតដំបូង និងកម្រិតធ្ងន់សម្រាប់ស្ត្រី។

## IV. អត្ថប្រយោជន៍នៃការធានា

បណ្ណសន្យារ៉ាប់រងរបស់អ្នកផ្តល់ជូននូវអត្ថប្រយោជន៍ផ្សេងៗ ស្របតាម ខ និងលក្ខខណ្ឌដូចបានកំណត់ខាងក្រោម÷

### ១. សំណងមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍

ប្រសិនបើអ្នកត្រូវបានធានារ៉ាប់រងទទួលមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ក្នុងអំឡុងពេលដែលបណ្ណសន្យារ៉ាប់រងនេះកំពុងមានសុពលភាព និងមុនកាលបរិច្ឆេទផុតកំណត់នៃបណ្ណសន្យារ៉ាប់រង ក្រុមហ៊ុននឹងផ្តល់សំណងជូនអ្នក ឬអ្នកទទួលផល ទៅតាមករណីជាក់ស្តែងនូវចំនួនទឹកប្រាក់ត្រូវបានធានារ៉ាប់រងសម្រាប់បណ្ណសន្យារ៉ាប់រងផលិតផលមូលដ្ឋាននេះនៅពេលអ្នកត្រូវបានធានារ៉ាប់រង

ទទួលមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ ដោយដកចេញនូវបំណុលនានានៃបណ្ណសន្យារ៉ាប់រងនេះប្រសិនបើមាន។ បន្ទាប់មកបណ្ណសន្យារ៉ាប់រងនេះត្រូវបានបញ្ចប់។

**២. អត្ថប្រយោជន៍រស់រានមានជីវិត និងអត្ថប្រយោជន៍បង្កក់ខែកូន**

ប្រសិនបើអ្នកត្រូវបានធានារ៉ាប់រងនៅបន្តរស់រានមានជីវិតនៅខួបនៃបណ្ណសន្យារ៉ាប់រងដែលបានកំណត់ ឬអ្នកត្រូវបានធានារ៉ាប់រងនៅរស់រានមានជីវិត ហើយទារកទារិកាក្នុងការសម្រាលកូនមួយលើកៗមានអាយុបាន ៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីផុតរយៈពេលរង់ចាំ នៅក្នុងរយៈពេលនៃឆ្នាំបណ្ណសន្យារ៉ាប់រងដែលបានកំណត់ ក្រុមហ៊ុននឹងផ្តល់ជូនអ្នកនូវអត្ថប្រយោជន៍នៅរស់រានមានជីវិត និងអត្ថប្រយោជន៍បង្កក់ខែកូនដែលត្រូវគណនាតាមអត្រាសមាមាត្រនៃចំនួនទឹកប្រាក់ត្រូវបានធានារ៉ាប់រងនៃផលិតផលមូលដ្ឋាន នៅថ្ងៃខួបបណ្ណសន្យារ៉ាប់រង ឬថ្ងៃបង្កក់ខែកូនដែលត្រូវទទួលបាន។ តាមតារាងខាងក្រោមបង្ហាញអំពីអត្រាសមាមាត្រជាក់ស្តែងនៃចំនួនទឹកប្រាក់ត្រូវបានធានារ៉ាប់រងនៃផលិតផលមូលដ្ឋានដែលត្រូវទទួលបាន÷

| ឆ្នាំបណ្ណសន្យារ៉ាប់រង | អត្ថប្រយោជន៍បង្កក់ខែកូន | ភាគរយនៃចំនួនទឹកប្រាក់ត្រូវបានធានា |
|---|---|---|
| ទី ២ ដល់ ៥ | រហូតដល់ការសម្រាលកូនចំនួន២ (ពីរ) លើក* | ២% សម្រាប់ការសម្រាលកូនក្នុងមួយលើក |

| ខួបនៃបណ្ណសន្យារ៉ាប់រង | អត្ថប្រយោជន៍រស់រានមានជីវិត | ភាគរយនៃទឹកប្រាក់ត្រូវបានធានា |
|---|---|---|
| ៥ | អត្ថប្រយោជន៍ខួប៥ឆ្នាំនៃបណ្ណសន្យារ៉ាប់រង | ១០% ដោយត្រូវដកចេញនូវចំនួនអត្ថប្រយោជន៍បង្កក់ខែកូនសរុបដែលបានទូទាត់រួចក្នុងចន្លោះឆ្នាំបណ្ណសន្យារ៉ាប់រងទី២ដល់ទី៥ ប្រសិនបើមាន |
| ៦ | អត្ថប្រយោជន៍ថែទាំសុខភាព** | ១% |
| ៨ | | ១% |
| ១០ | | ១% |
| ១២ | | ១% |
| ១៤ | | ១% |

| | | |
|---|---|---|
| ១៦ | | ២% |
| ១៨ | | ២% |
| ២០ | | ២% |
| ២២ | | ២% |
| ២៤ | | ២% |
| ដល់កាលកំណត់ | អត្ថប្រយោជន៍ដល់កាលកំណត់ | ៥០% |

**កំណត់សម្គាល់÷**

* ត្រូវបំពេញតាមលក្ខខណ្ឌនៃរយៈពេលរង់ចាំ១ (មួយ) ឆ្នាំសម្រាប់ការសម្រាលកូនលើកដំបូងក្រោយបណ្ណសន្យារ៉ាប់រងចាប់ផ្តើមមានសុពលភាព។ អត្ថប្រយោជន៍បង្កក់ខែកូន (២%(ពីរភាគរយ)នៃចំនួនទឹកប្រាក់ត្រូវបានធានាសម្រាប់ការសម្រាលកូនមួយលើកៗ) ត្រូវបានផ្តល់ជូនក្នុងករណីកូនមានអាយុបាន៣០ (សាមសិប)ថ្ងៃ ហើយដោយមិនគិតអំពីចំនួនកូននៃការសម្រាលម្តងៗនោះឡើយ។

** អត្ថប្រយោជន៍ថែទាំសុខភាពគឺមិនត្រូវបានផ្តល់ជូននៅពេលបណ្ណសន្យារ៉ាប់រងដល់កាលកំណត់ឡើយ។

**៣. អត្ថប្រយោជន៍ជំងឺធ្ងន់ធ្ងរកម្រិតដំបូង និងជំងឺធ្ងន់ធ្ងរកម្រិតធ្ងន់សម្រាប់ស្ត្រី**

**៣.១. អត្ថប្រយោជន៍ជំងឺធ្ងន់ធ្ងរកម្រិតដំបូងសម្រាប់ស្ត្រី**

ក្រោយផុតរយៈពេលរង់ចាំ ប្រសិនបើអ្នកត្រូវបានធានារ៉ាប់រងត្រូវបានធ្វើរោគវិនិច្ឆ័យឃើញថាមានអាការៈជំងឺធ្ងន់ធ្ងរកម្រិតដំបូងដូចបានកំណត់ក្នុងតារាងជំងឺធ្ងន់ធ្ងរ នោះ ២៥%(ម្ភៃប្រាំភាគរយ)នៃចំនួនទឹកប្រាក់ត្រូវបានធានារ៉ាប់រងនៃផលិតផលមូលដ្ឋានដូចបានកំណត់ក្នុងវិញ្ញាបនបត្រធានារ៉ាប់រង ឬមានចំនួន២៥.០០០ (ពីរម៉ឺនប្រាំពាន់)ដុល្លារអាមេរិក ដោយយកចំនួនណាមួយតិចជាងគេ នឹងត្រូវផ្តល់ជូនអ្នកត្រូវបានធានារ៉ាប់រង។ បន្ទាប់ពីនេះគ្មានអត្ថប្រយោជន៍សម្រាប់ជំងឺធ្ងន់ធ្ងរកម្រិតដំបូងផ្សេងទៀត ត្រូវបានផ្តល់ជូនអ្នកត្រូវបានធានារ៉ាប់រងនោះឡើយ។ អត្ថប្រយោជន៍នៃជំងឺធ្ងន់ធ្ងរកម្រិតដំបូងសម្រាប់ស្ត្រីត្រូវបានផ្តល់ជូនអ្នកត្រូវបានធានារ៉ាប់រងតែម្តងប៉ុណ្ណោះសម្រាប់បណ្ណសន្យារ៉ាប់រងមួយនេះ។

នៅពេលដែលមានអត្ថប្រយោជន៍នៃជំងឺធ្ងន់ធ្ងរកម្រិតដំបូងសម្រាប់ស្ត្រីត្រូវបានទូទាត់ជូនរួចរាល់ ចំនួនទឹកប្រាក់នោះនឹងត្រូវដកចេញពីចំនួនទឹកប្រាក់ត្រូវបានធានារ៉ាប់រងនៃបណ្ណសន្យារ៉ាប់រងនៃផលិតផលមូលដ្ឋាន និងអត្ថប្រយោជន៍នៃជំងឺធ្ងន់ធ្ងរកម្រិតធ្ងន់សម្រាប់ស្ត្រី។

### ៣.២. អត្ថប្រយោជន៍ជំងឺធ្ងន់ធ្ងរកម្រិតធ្ងន់សម្រាប់ស្ត្រី

ក្រោយផុតរយៈពេលរង់ចាំ ប្រសិនបើអ្នកត្រូវបានធានារ៉ាប់រងត្រូវបានធ្វើរោគវិនិច្ឆ័យឃើញថាមានអាការៈជំងឺធ្ងន់ធ្ងរកម្រិតធ្ងន់ដូចបានកំណត់ក្នុងតារាងជំងឺធ្ងន់ធ្ងរ នោះ ១០០%(មួយរយភាគរយ)នៃចំនួនទឹកប្រាក់ត្រូវបានធានារ៉ាប់រងនៃផលិតផលមូលដ្ឋានដូចបានកំណត់ក្នុងវិញ្ញាបនបត្រធានារ៉ាប់រង ដោយដកចេញនៃចំនួនទឹកប្រាក់អត្ថប្រយោជន៍ជំងឺធ្ងន់ធ្ងរកម្រិតដំបូងសម្រាប់ស្ត្រីដែលបានទូទាត់ជូនរួចរាល់ប្រសិនបើមាន និងដកចេញនូវបំណុលនានានៃបណ្ណសន្យារ៉ាប់រងនេះប្រសិនបើមាន។ នៅពេលអត្ថប្រយោជន៍ជំងឺធ្ងន់ធ្ងរកម្រិតធ្ងន់សម្រាប់ស្ត្រីបានទូទាត់ជូនរួចរាល់បណ្ណសន្យារ៉ាប់រងនេះត្រូវបានបញ្ចប់ដោយស្វ័យប្រវត្តិ ។

**៣.៣.** ចំនួនទឹកប្រាក់សរុបដែលបានទូទាត់ជូនស្របតាមអត្ថប្រយោជន៍ជំងឺធ្ងន់ធ្ងរកម្រិតដំបូងសម្រាប់ស្ត្រី(ចំនុច៣.១.) និងអត្ថប្រយោជន៍ជំងឺធ្ងន់ធ្ងរកម្រិតធ្ងន់សម្រាប់ស្ត្រី (ចំនុច៣.២.) មិនត្រូវលើសពី ១០០%(មួយរយភាគរយ)នៃចំនួនទឹកប្រាក់ត្រូវបានធានារ៉ាប់រងនៃផលិតផលមូលដ្ឋានដូចបានកំណត់ក្នុងវិញ្ញាបនបត្រធានារ៉ាប់រងឡើយ។

**៣.៤.** ប្រសិនបើមានការទាមទារសំណងចំនួន២(ពីរ) ឬលើសច្រើនជាងនេះក្នុងពេលដំណាលគ្នាស្របតាមចំណាត់ថ្នាក់ជំងឺធ្ងន់ធ្ងរក្នុងកម្រិតផ្សេងៗគ្នា យើងខ្ញុំនឹងធ្វើការទូទាត់ជូនតែមួយករណីប៉ុណ្ណោះ នូវចំនួនអត្ថប្រយោជន៍ណាដែលអាចទាមទារសំណងបានច្រើនជាងគេបំផុតដែលអនុម័តដោយយើងខ្ញុំ។

**៣.៥.** ប្រសិនបើមានការទាមទារសំណងចំនួន២(ពីរ) ឬលើសច្រើនជាងនេះស្របតាមចំណាត់ថ្នាក់ជំងឺធ្ងន់ធ្ងរក្នុងកម្រិតផ្សេងៗគ្នាដែលត្រូវបានធ្វើរោគវិនិច្ឆ័យឃើញក្នុងពេលដំណាលគ្នា យើងខ្ញុំនឹងធ្វើការទូទាត់ជូនតែមួយករណីប៉ុណ្ណោះ នូវចំនួនអត្ថប្រយោជន៍ណាដែលអាចទាមទារសំណងបានច្រើនជាងគេបំផុតដែលអនុម័តដោយយើងខ្ញុំ។

**៣.៦.** នៅពេលដែលមានការទូទាត់ជូនរួចរាល់ចំពោះការទាមទារសំណងនៃអត្ថប្រយោជន៍ជំងឺធ្ងន់ធ្ងរស្របតាមចំណាត់ថ្នាក់ជំងឺធ្ងន់ធ្ងរក្នុងកម្រិតណាមួយហើយនោះ នឹងគ្មានការទូទាត់នូវអត្ថប្រយោជន៍ជំងឺធ្ងន់ធ្ងរដែលចំណាត់ថ្នាក់ជំងឺធ្ងន់ធ្ងរក្នុងកម្រិតដូចគ្នាទៀតឡើយ។

**៣.៧.** វិសាលភាពនៃជំងឺធ្ងន់ធ្ងរដែលត្រូវបានធានា ស្របតាមកិច្ចសន្យាធានារ៉ាប់រងនេះអាចត្រូវបានពិនិត្យឡើងវិញដោយយើងខ្ញុំពីពេលមួយទៅពេលមួយ ប៉ុន្តែយើងខ្ញុំនឹងជូនដំណឹងដល់អ្នកជាលាយលក្ខណ៍អក្សររយៈពេល ៩០ (កៅសិប) ថ្ងៃមុនពេលការកែប្រែចាប់ផ្តើមមានសុពលភាព។

រាល់បំណុលទាំងឡាយនៃបណ្ណសន្យារ៉ាប់រងនេះ នឹងត្រូវកាត់ចេញពីចំនួនទឹកប្រាក់ដែលត្រូវទូទាត់ជូន នៅពេលធ្វើការទូទាត់អត្ថប្រយោជន៍ ឬសំណងធានារ៉ាប់រងដូចបានរៀបរាប់ខាងលើស្របតាមបណ្ណសន្យារ៉ាបរងនេះ។

ខ និងលក្ខខណ្ឌទាំងនេះត្រូវជំនួសបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីនេះ ដែលអាចត្រូវបានភ្ជាប់ជាមួយ ឬដាក់ជាផ្នែកនៃបណ្ណសន្យារ៉ាប់រងនេះ។

## V. ខ និងបញ្ញត្តិស្តីពីបុព្វលាភធានារ៉ាប់រង

### ១. បុព្វលាភធានារ៉ាប់រង

បុព្វលាភធានារ៉ាប់រងនៃបណ្ណសន្យារ៉ាប់រងនេះអាចត្រូវបានកែប្រែដោយយើងខ្ញុំ ដោយសារកត្តាមួយចំនួនដែលរួមបញ្ចូល ប៉ុន្តែមិនកំណត់ត្រឹមអាយុដែលទទួលបានការធានា មុខងាររបស់អ្នកត្រូវបានធានា និងប្រភេទនៃអាការៈជំងឺធ្ងន់ធ្ងរដែលត្រូវបានធានា ស្របតាមបណ្ណសន្យារ៉ាប់រងនេះ។ ទោះយ៉ាងនេះក្តី យើងខ្ញុំនឹងជូនដំណឹងជាលាយលក្ខណ៍អក្សររយៈពេល ៩០ (កៅសិប) ថ្ងៃមុនការកែប្រែមានអានុភាពអនុវត្ត។

### ២. ការបង់បុព្វលាភធានារ៉ាប់រង

រាល់បុព្វលាភធានារ៉ាប់រងសម្រាប់បណ្ណសន្យារ៉ាប់រងនេះត្រូវទូទាត់មកយើងខ្ញុំ នៅកាលបរិច្ឆេទ ឬមុនកាលបរិច្ឆេទដល់កាលកំណត់ត្រូវបង់បុព្វលាភធានារ៉ាប់រង ទៅតាមវិធីសាស្ត្រដែលយើងខ្ញុំបានកំណត់។ លិខិតតម្កល់ប្រាក់ដែលមានសុពលភាព ឬការកាត់បុព្វលាភធានារ៉ាប់រងចេញពីគណនីដែលបង្ហាញក្នុងរបាយការណ៍គណនីរបស់អ្នកត្រូវបានចាត់ទុកថាជាភស្តុតាងនៃការបានបង់ប្រាក់រួច។

### ៣. ការផ្លាស់ប្តូរ

អ្នកអាចផ្លាស់ប្តូរវិធីសាស្ត្របង់បុព្វលាភធានារ៉ាប់រងបាន ដោយដាក់ពាក្យស្នើសុំជាលាយលក្ខណ៍អក្សរមកកាន់យើងខ្ញុំ។ អនុលោមតាមលក្ខខណ្ឌអប្បបរមានៃបុព្វលាភធានារ៉ាប់រងរបស់យើងខ្ញុំ បុព្វលាភធានារ៉ាប់រងអាចត្រូវបានបង់ជាប្រចាំឆ្នាំ ឬប្រចាំឆមាស ឬប្រចាំត្រីមាសតាមអត្រាដែលត្រូវអនុវត្តនៅកាលបរិច្ឆេទមានសុពលភាពនៃបណ្ណសន្យារ៉ាប់រង។

### ៤. ការបំពាន

បន្ទាប់ពីការបង់បុព្វលាភធានារ៉ាប់រងដំបូង ការខកខានក្នុងការបង់បុព្វលាភធានារ៉ាប់រងបន្តបន្ទាប់នៅកាលបរិច្ឆេទដល់កាលកំណត់ត្រូវបង់ ឬមុនកាលបរិច្ឆេទដល់កាលកំណត់ត្រូវបង់ នឹងត្រូវបានចាត់ទុកជាការបំពានលក្ខខណ្ឌបង់បុព្វលាភធានារ៉ាប់រង។ ប្រសិនបើបុព្វលាភធានារ៉ាប់រងនៅតែមិនទាន់បានបង់បន្ទាប់ពីរយៈពេលអនុគ្រោះដល់កាលកំណត់ បណ្ណសន្យារ៉ាប់រងនឹងត្រូវផ្អាកសុពលភាព គិតចាប់ពីថ្ងៃបន្ទាប់នៃថ្ងៃផុតកំណត់នៃរយៈពេលអនុគ្រោះ។

### ៥. ការកាត់យកបុព្វលាភធានារ៉ាប់រងនៅពេលមរណភាព ឬពិការភាព ឬជំងឺធ្ងន់ធ្ងរកម្រិតធ្ងន់សម្រាប់ស្ត្រី

នៅពេលដែលអ្នកត្រូវបានធានារ៉ាប់រងទទួលមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ ឬការធ្វើរោគវិនិច្ឆ័យរកឃើញជំងឺធ្ងន់ធ្ងរកម្រិតធ្ងន់ សមតុល្យនៃបុព្វលាភធានារ៉ាប់រងដែលដល់កាលកំណត់ត្រូវបង់រហូតដល់ពេលចុងបញ្ចប់នៃឆ្នាំនៃបណ្ណសន្យារ៉ាប់រងដែលមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ ឬការធ្វើរោគវិនិច្ឆ័យជំងឺធ្ងន់ធ្ងរកម្រិតធ្ងន់ ត្រូវកាត់កងចេញពីសំណងធានារ៉ាប់រងដែលត្រូវទូទាត់ជូន ស្របតាមបណ្ណសន្យារ៉ាប់រងនេះ។

## VI. ករណីមិនធានា

បណ្ណសន្យារ៉ាប់រងនេះមិនផ្តល់ការការពារចំពោះ÷

### ១. មរណភាព

មិនមានសំណងមរណភាពនឹងត្រូវផ្តល់ជូននោះទេ ប្រសិនបើមរណភាពរបស់អ្នកត្រូវបានធានារ៉ាប់រង ត្រូវបានបង្កឡើងដោយផ្ទាល់ ឬដោយប្រយោល ទាំងស្រុង ឬដោយផ្នែក ដោយសារព្រឹត្តិការណ៍ណាមួយដូចខាងក្រោម÷

(១) ការធ្វើអត្តឃាតក្នុងរយៈពេល ២ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទចាប់ផ្តើមសុពលភាពនៃបណ្ណសន្យារ៉ាប់រង ឬកាលបរិច្ឆេទនៃការដាក់បន្តសុពលភាពបណ្ណសន្យារ៉ាប់រងឡើងវិញ ដោយយកកាលបរិច្ឆេទណាមួយចុងក្រោយ។

(២) ការប្រព្រឹត្ត ឬប៉ុនប៉ងប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ។

(៣) វីរុសហ៊ីវ និង/ ឬជំងឺណាមួយដែលជាប់ទាក់ទងនឹងវីរុសហ៊ីវ ដែលរួមមានទាំងជំងឺអេដស៍ និង/ ឬការបំលែង ការវិវត្តន៍ ឬការប្រែប្រួលនៃមេរោគអេដស៍។

(៤) ការប្រើប្រាស់ថ្នាំញៀន ឬថ្នាំភ្លេចអារម្មណ៍ ឬការសេពគ្រឿងស្រវឹងហួសកម្រិត ឬបើកបរយានជំនិះក្រោមឥទ្ធិពលនៃគ្រឿងស្រវឹង ឬផលវិបាកផ្សេងៗនៃអំពើទាំងនេះ ដូចដែលបានកំណត់ដោយច្បាប់ដែលបានចូលជាធរមាន។

## ២.ពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍

ក្រុមហ៊ុនមិនធានាលើការបាត់បង់ ឬពិការភាពដែលកើតឡើងដោយផ្ទាល់ ឬដោយប្រយោលទាំងស្រុង ឬ ដោយផ្នែក ដោយសារព្រឹត្តិការណ៍ណាមួយដូចខាងក្រោម÷

(១) ការធ្វើអត្តឃាត ឬប៉ុនប៉ងធ្វើអត្តឃាត ឬធ្វើឲ្យរបួសខ្លួនឯង ទោះស្ថិតក្នុងស្ថានភាពផ្លូវចិត្តប្រក្រតី ឬមិនប្រក្រតីក៏ដោយ។

(២) ការឆ្លងវីរុសហ៊ីវ រោគសញ្ញានៃជំងឺអេដស៍ ឬជំងឺដែលទាក់ទងនឹងជំងឺអេដស៍។

(៣) សង្គ្រាម (មិនថាបានប្រកាស ឬមិនបានប្រកាស) ការឈ្លានពាន សកម្មភាពលុកលុយរបស់សត្រូវបរទេស សង្គ្រាមស៊ីវិល បដិវត្តន៍ ចលនាបះបោរ ចលាចលស៊ីវិល ការធ្វើកុបកម្ម ការធ្វើភូដកម្ម ការបះបោរប្រឆាំងនឹងរដ្ឋាភិបាល និងអំពើភេរវកម្ម។

(៤) ខណៈពេលដែលអ្នកត្រូវបានធានារ៉ាប់រងប្រព្រឹត្តបទឧក្រិដ្ឋ ឬខណៈពេលដែលអ្នកត្រូវបានធានារ៉ាប់រងកំពុងត្រូវបានតាមចាប់ខ្លួន ឬត្រូវរងការចាប់ខ្លួន ឬកំពុងរត់គេចពីការចាប់ខ្លួន។

(៥) ការធ្វើដំណើរចូល ការចាកចេញ ការធ្វើប្រតិបត្តិការបញ្ជា ការធ្វើប្រតិបត្តិការជួសជុលថែទាំ ឬត្រូវបានដឹកជញ្ជូនដោយ យានឬមធ្យោបាយធ្វើដំណើរតាមផ្លូវអាកាសនានា លើកលែងតែក្នុងករណីអ្នកត្រូវបានធានារ៉ាប់រងគឺជាអ្នកដំណើរបង់ប្រាក់ធម្មតា ឬអ្នកបម្រើការលើយន្តហោះនៃក្រុមហ៊ុនអាកាសចរណ៍ពាណិជ្ជមួយ ដែលធ្វើប្រតិបត្តិការជាទៀងទាត់តាមកាលវិភាគ និងតាមគន្លងផ្លូវដឹកជញ្ជូនអ្នកដំណើរផ្លូវអាកាសដែលបានកំណត់ជាមុនរបស់ក្រុមហ៊ុន។

(៦) ខណៈពេលដែលអ្នកត្រូវបានធានារ៉ាប់រងបំពេញកាតព្វកិច្ចជាយោធា ប៉ូលីស ឬជាអ្នកស្ម័គ្រចិត្តចូលរួមក្នុងសង្គ្រាម ឬការបង្ក្រាបឧក្រិដ្ឋកម្ម។

(៧) ស្ថានភាពដែលមានពីមុនស្រាប់ មុនកាលបរិច្ឆេទចាប់ផ្តើមសុពលភាពនៃបណ្ណសន្យារ៉ាប់រង ឬកាលបរិច្ឆេទនៃការដាក់បន្តសុពលភាពបណ្ណសន្យារ៉ាប់រងឡើងវិញ ដោយយកកាលបរិច្ឆេទចុង

ក្រោយគេ។ ស្ថានភាពដែលមានពីមុនស្រាប់ មានន័យថាជាជំងឺដែលអ្នកត្រូវបានធានារ៉ាប់រងបានដឹងច្បាស់ លុះត្រាតែស្ថានភាពទាំងនោះត្រូវបានប្រកាសមកកាន់ក្រុមហ៊ុន និងទទួលយកដោយក្រុមហ៊ុន។ អ្នកត្រូវបានធានារ៉ាប់រងអាចត្រូវបានចាត់ទុកថាបានដឹងច្បាស់អំពីស្ថានភាពដែលមានពីមុនស្រាប់ ប្រសិនបើមានស្ថានភាពណាមួយដូចបានចែងខាងក្រោម÷

ក) អ្នកត្រូវបានធានារ៉ាប់រងបានទទួល ឬកំពុងទទួលការព្យាបាល

ខ) យោបល់វេជ្ជសាស្ត្រ ការធ្វើរោគវិនិច្ឆ័យ ការថែទាំ ឬការព្យាបាលផ្នែកវេជ្ជសាស្ត្រត្រូវបានណែនាំ

គ) មានរោគសញ្ញាច្បាស់ និងជាក់លាក់ត្រូវបានបង្ហាញ ឬ

ឃ) វត្តមាននៃស្ថានភាពនោះអាចត្រូវបានកត់សម្គាល់ដោយបុគ្គលទូទៅក្នុងកាលៈទេសៈណាមួយ។

(៨) អ្នកត្រូវបានធានារ៉ាប់រងស្ថិតនៅក្រោមឥទ្ធិពលនៃគ្រឿងស្រវឹង ឬការប្រើប្រាស់ថ្នាំណាមួយលើកលែងតែស្ថិតក្រោមការណែនាំរបស់គ្រូពេទ្យដែលមានអាជ្ញាបណ្ណត្រឹមត្រូវ។

(៩) ការចូលរួមក្នុងសកម្មភាពកីឡាគ្រោះថ្នាក់រួមមាន តែមិនកំណត់ត្រឹមការជ្រមុជទឹក ការឡើងភ្នំ ការលោតឆ័ត្រយោង ឬការប្រណាំងល្បឿនលឿនណាមួយ ឬសកម្មភាពកីឡាអាជីព។

### ៣. ជំងឺធ្ងន់ធ្ងរសម្រាប់ស្ត្រី

ក្រុមហ៊ុនមិនផ្តល់សំណងចំពោះជំងឺធ្ងន់ធ្ងរសម្រាប់ស្ត្រីទាំងឡាយណាដែលកើតឡើងដោយផ្ទាល់ ឬដោយប្រយោលមកពីព្រឹត្តិការណ៍ណាមួយដូចខាងក្រោម÷

១. ជំងឺផ្សេងទៀតក្រៅពីរោគវិនិច្ឆ័យជំងឺធ្ងន់ធ្ងរ ដូចមានកំណត់នៅក្នុងកិច្ចសន្យានេះ។

២. ជំងឺអេដស៍ ឬជំងឺបណ្តាលមកពីជំងឺអេដស៍ ឬជំងឺពាក់ព័ន្ធនឹងវីរុសហ៊ីវ។

៣. ស្ថានភាពដែលមានពីមុនស្រាប់ មុនកាលបរិច្ឆេទចាប់ផ្តើមសុពលភាពនៃបណ្ណសន្យារ៉ាប់រង ឬកាលបរិច្ឆេទនៃការដាក់បន្តសុពលភាពបណ្ណសន្យារ៉ាប់រងឡើងវិញ ដោយយកកាលបរិច្ឆេទចុងក្រោយគេ។ ស្ថានភាពដែលមានពីមុនស្រាប់ មានន័យថាជាជំងឺដែលអ្នកត្រូវបានធានារ៉ាប់រងបានដឹងច្បាស់ លុះត្រាតែស្ថានភាពទាំងនោះត្រូវបានប្រកាសមកកាន់ក្រុមហ៊ុន និងទទួលយកដោយក្រុមហ៊ុន។ អ្នកត្រូវបានធានារ៉ាប់រងអាចត្រូវបានចាត់ទុកថាបានដឹងច្បាស់អំពីស្ថានភាពដែលមានពីមុនស្រាប់ ប្រសិនបើមានស្ថានភាពណាមួយដូចបានចែងខាងក្រោម÷

ក) អ្នកដែលត្រូវបានធានាបានទទួល ឬកំពុងទទួលការព្យាបាល

ខ) យោបល់វេជ្ជសាស្ត្រ ការធ្វើរោគវិនិច្ឆ័យ ការថែទាំ ឬការព្យាបាលផ្នែកវេជ្ជសាស្ត្រត្រូវបានណែនាំ

គ) មានរោគសញ្ញាច្បាស់ និងជាក់លាក់ត្រូវបានបង្ហាញ ឬ

ឃ) វត្តមាននៃស្ថានភាពនោះអាចត្រូវបានកត់សម្គាល់ដោយបុគ្គលទូទៅក្នុងកាលៈទេសៈណាមួយ។

៤. អ្នកត្រូវបានធានារ៉ាប់រងស្ថិតនៅក្រោមឥទ្ធិពលនៃគ្រឿងស្រវឹង ឬការប្រើប្រាស់ថ្នាំណាមួយលើកលែងតែស្ថិតក្រោមការណែនាំរបស់គ្រូពេទ្យដែលមានអាជ្ញាបណ្ណត្រឹមត្រូវ។

៥. ជំងឺធ្ងន់ធ្ងរទាំងអស់ដែលកើតមាន ឬធ្វើរោគវិនិច្ឆ័យរកឃើញក្នុងរយៈពេលរង់ចាំដោយរាប់បញ្ចូលទាំងជំងឺធ្ងន់ធ្ងរកម្រិតដំបូង ដែលត្រូវបានរកឃើញពេលធ្វើរោគវិនិច្ឆ័យដំបូងក្នុងរយៈពេលរង់ចាំ ហើយវិវត្តទៅជាជំងឺធ្ងន់ធ្ងរកម្រិតធ្ងន់បន្ទាប់ពីរយៈពេលរង់ចាំត្រូវបានផុតកំណត់។

៦. ជំងឺកើតចេញពីការសាយភាយដោយផ្ទាល់ ឬដោយប្រយោលនូវធាតុវិទ្យុសកម្មពីថាមពលនុយក្លេអ៊ែរ ឬសំណល់នុយក្លេអ៊ែរ ដែលបង្កឡើងដោយដំណើរការបំលែងថាមពលនុយក្លេអ៊ែរ ឬអាវុធនុយក្លេអ៊ែរ។

## VII. ទីតាំងភូមិសាស្ត្រនៃការធានា

ទូទាំងពិភពលោក។

## VIII. អ្នកទទួលផល

ម្ចាស់បណ្ណសន្យារ៉ាប់រង/អ្នក ដែលអាចជាអ្នកត្រូវបានធានារ៉ាប់រងផងដែរនោះអាចចាត់តាំងបុគ្គលណាម្នាក់ក្នុងការទទួលប្រាក់ដែលនឹងត្រូវបង់ជូននាពេលអ្នកទទួលមរណភាព។ អ្នកអាចកំណត់ឈ្មោះអ្នកទទួលផលម្នាក់ ឬច្រើននាក់ នៅពេលដាក់ពាក្យស្នើសុំ ឬនៅពេលណាមួយក៏បាន ក្រោយពេលដែលបណ្ណសន្យារ៉ាប់រងនេះត្រូវបានចេញជូនក្នុងពាក្យស្នើសុំដែលបានកំណត់ដោយយើងខ្ញុំ។

ដោយអនុលោមតាមច្បាប់ អ្នកមានសិទ្ធិក្នុងការដកហូតការតែងតាំងណាមួយ និង/ឬ តែងតាំងអ្នកទទួលផលផ្សេងម្នាក់ ឬច្រើននាក់ផ្សេងទៀត ដោយជូនដំណឹងជាលាយលក្ខណ៍អក្សរមកកាន់យើងខ្ញុំ។ ការ

ជូនដំណឹងជាលាយលក្ខណ៍អក្សររបស់អ្នកត្រូវតែទទួលបាន និងកត់ត្រាដោយយើងខ្ញុំសម្រាប់អំឡុងពេលនៅរស់រានមានជីវិតរបស់អ្នក។

ប្រសិនបើអ្នកត្រូវបានធានារ៉ាប់រងមានបំណងចង់ដកហូត ឬផ្លាស់ប្តូរអ្នកទទួលផលបច្ចុប្បន្នណាមួយ ដំបូងអ្នកត្រូវបានធានារ៉ាប់រងត្រូវតែជាម្ចាស់បណ្ណសន្យារ៉ាប់រងជាមុនសិន។ បន្ទាប់មកតាមរយៈការជូនដំណឹងជាលាយលក្ខណ៍អក្សរមកកាន់យើងខ្ញុំ និងដាក់ពាក្យស្នើសុំឲ្យបានត្រឹមត្រូវ អ្នកត្រូវបានធានារ៉ាប់រងអាចដំណើរការការដកហូត និងតែងតាំងអ្នកទទួលផលម្នាក់ ឬច្រើននាក់ផ្សេងទៀត។ ការដកហូត និងការផ្លាស់ប្តូរអ្នកទទួលផលណាមួយ ត្រូវមានប្រសិទ្ធិភាពចាប់ពីថ្ងៃដែលលិខិតជូនដំណឹងជាលាយ លក្ខណ៍អក្សរនោះបានប្រគល់មកដល់យើងខ្ញុំ។

ក្នុងករណីអ្នកបានតែងតាំងអ្នកទទួលផលលើសពីមួយនាក់ យើងខ្ញុំត្រូវផ្តល់ប្រាក់ដែលនឹងត្រូវបង់ទៅឲ្យបុគ្គលដែលទទួលបានការតែងតាំងដោយអ្នក ហើយនៅរស់រានមានជីវិតបន្ទាប់ពីមរណភាពរបស់អ្នកត្រូវបានធានារ៉ាប់រង ក្នុងចំណែកស្មើៗគ្នា លើកលែងតែអ្នកបានកំណត់ផ្សេងពីនេះ។ ការបែងចែកនេះនឹងត្រូវធ្វើឡើងដោយអនុលោមតាមច្បាប់ជាធរមាននាពេលនោះ។ ការទូទាត់ប្រាក់នេះ នឹងត្រូវបានចាត់ទុកថាជាការដោះបន្ទុកនៃការបង់ប្រាក់ស្រមតាមបណ្ណសន្យារ៉ាប់រងនេះ។

ក្នុងករណីអ្នកត្រូវបានធានារ៉ាប់រងទទួលមរណភាព ហើយពុំមានអ្នកទទួលផលណាម្នាក់ត្រូវបានតែងតាំង ឬអ្នកទទួលផលនោះបានទទួលមរណភាព ទឹកប្រាក់ទាំងនោះអាចនឹងត្រូវបង់ជូនសាច់ញាតិរបស់អ្នកទទួលផលនោះ។ ករណីនេះនឹងត្រូវអនុវត្ត ស្របតាមច្បាប់ជាធរមាននាពេលនោះ។

## IX. ការកែប្រែកិច្ចសន្យាធានារ៉ាប់រង

មិនត្រូវបានអនុវត្ត។

## X. ការបន្តកិច្ចសន្យាធានារ៉ាប់រង

ប្រសិនបើបុព្វលាភធានារ៉ាប់រងនៅតែមិនត្រូវបានបង់បន្ទាប់ពីរយៈពេលអនុគ្រោះ ដែលបានកំណត់ខាងលើ បណ្ណសន្យារ៉ាប់រងផលិតផលមូលដ្ឋាននេះអាចត្រូវបានដាក់បន្តសុពលភាពឡើងវិញតាមការសម្រេចរបស់យើងខ្ញុំ។ ប៉ុន្តែការដាក់បន្តសុពលភាពបណ្ណសន្យារ៉ាប់រងឡើងវិញនេះត្រូវធ្វើឡើងក្នុងរយៈពេល ២ (ពីរ) ឆ្នាំគិតចាប់ពីកាលបរិច្ឆេទផ្អាកសុពលភាព និងក្នុងលក្ខខណ្ឌដូចខាងក្រោម÷

១. ពាក្យស្នើសុំជាលាយលក្ខណ៍អក្សរពីអ្នកស្នើសុំដាក់បន្តសុពលភាពបណ្ណសន្យារ៉ាប់រងឡើងវិញ ។

២. អ្នកត្រូវបានធានារ៉ាប់រងមានអាយុដែលអាចអនុញ្ញាតឱ្យទទួលការធានាបាន ដូចបានកំណត់ដោយយើងខ្ញុំនៅពេលដាក់បន្តសុពលភាពបណ្ណសន្យារ៉ាប់រងឡើងវិញ ។

៣. អ្នកត្រូវបានធានារ៉ាប់រងត្រូវបង្ហាញភស្តុតាងនៃភាពអាចធានារ៉ាប់រងបាន ដូចបានកំណត់ដោយយើងខ្ញុំនៅពេលដាក់បន្តសុពលភាពបណ្ណសន្យារ៉ាប់រងឡើងវិញ ។

៤. ការទូទាត់រាល់បុព្វលាភធានារ៉ាប់រងដែលហួសពេលកំណត់បង់ ជាមួយនឹងប្រាក់ពិន័យក្នុងអត្រាដែលកំណត់ដោយយើងនៅពេលហួសពេលកំណត់។

៥. ការទូទាត់បំណុលដែលមិនទាន់បានទូទាត់នៅពេលដែលពាក់ព័ន្ធ ជាមួយនឹងប្រាក់ពិន័យក្នុងអត្រាដែលកំណត់ដោយយើងខ្ញុំ និង

៦. ខ និងលក្ខខណ្ឌដទៃផ្សេងទៀតដែលយើងខ្ញុំអាចនឹងដាក់នៅពេលដែលពាក់ព័ន្ធ។

នៅពេលដាក់បន្តសុពលភាពបណ្ណសន្យារ៉ាប់រងឡើងវិញ បណ្ណសន្យារ៉ាប់រងនឹងត្រូវមានសុពលភាពចាប់ពីកាលបរិច្ឆេទនៃការដាក់បន្តសុពលភាពបណ្ណសន្យារ៉ាប់រងឡើងវិញនោះ។ ប្រាក់ពិន័យលើបុព្វលាភធានារ៉ាប់រង និងបំណុលដែលកើតចេញពីបណ្ណសន្យារ៉ាប់រង (ប្រសិនបើមាន) នឹងត្រូវគិតបញ្ចូលគ្នារហូតដល់កាលបរិច្ឆេទនៃការដាក់បន្តសុពលភាពបណ្ណសន្យារ៉ាប់រងឡើងវិញ ក្នុងអត្រាប្រចាំឆ្នាំដែលបានកំណត់ដោយយើងខ្ញុំ។ គ្មានការធានារ៉ាប់រងត្រូវបានផ្តល់ជូនស្របតាមបណ្ណសន្យារ៉ាប់រងនេះក្នុងអំឡុងពេលដែលបណ្ណសន្យារ៉ាប់រងផ្អាកសុពលភាព រហូតដល់កាលបរិច្ឆេទនៃការដាក់បន្តសុពលភាពបណ្ណសន្យារ៉ាប់រងឡើងវិញ។

ការដាក់បន្តសុពលភាពបណ្ណសន្យារ៉ាប់រងឡើងវិញណាមួយត្រូវធានារ៉ាប់រងតែលើការបាត់បង់ ឬព្រឹត្តិការណ៍ត្រូវបានធានារ៉ាប់រងដែលកើតឡើង បន្ទាប់ពីកាលបរិច្ឆេទនៃការដាក់បន្តសុពលភាពបណ្ណសន្យារ៉ាប់រងឡើងវិញប៉ុណ្ណោះ។

## XI. ការបញ្ចប់កិច្ចសន្យាធានារ៉ាប់រង

អ្នកមានសិទ្ធិក្នុងការបញ្ចប់បណ្ណសន្យារ៉ាប់រងនេះដោយស្នើសុំជាលាយលក្ខណ៍អក្សរមកកាន់យើងខ្ញុំតាមទម្រង់ដែលយើងខ្ញុំបានកំណត់នៅពេលណាក៏បាន។ ប្រសិនបើអ្នកស្នើសុំបញ្ចប់បណ្ណសន្យារ៉ាប់រងក្នុងរយៈពេលសម្រេចចិត្ត យើងខ្ញុំនឹងផ្តល់ត្រឡប់ជូនអ្នកវិញនូវបុព្វលាភធានារ៉ាប់រងដែលអ្នកបានបង់ បន្ទាប់ពីធ្វើការទូទាត់ជាមួយនឹងចំណាយនានាពាក់ព័ន្ធនឹងការពិនិត្យសុខភាព។ ប្រសិនបើអ្នកស្នើសុំបញ្ចប់បណ្ណសន្យារ៉ាប់រងនេះបន្ទាប់ពីផុតរយៈពេលសម្រេចចិត្ត យើងខ្ញុំនឹងផ្តល់ជូនអ្នកវិញនូវតម្លៃសាច់ប្រាក់ដូចមានចែងនៅក្នុងវិញ្ញាបនបត្រធានារ៉ាប់រង ដោយដកចេញនូវប្រាក់ដែលបានជំពាក់នានា (ប្រសិនបើមាន) និងដោយ

អនុលោមតាមប្រការពាក់ព័ន្ធនឹងតម្លៃសាច់ប្រាក់នៃបណ្ណសន្យារ៉ាប់រង ដូចមានចែងនៅក្នុងបណ្ណសន្យារ៉ាប់រងនេះ។ បន្ទាប់ពីយើងខ្ញុំបានបង់ត្រឡប់បុព្វលាភធានារ៉ាប់រង ឬតម្លៃសាច់ប្រាក់ជូនអ្នករួចរាល់ បណ្ណសន្យារ៉ាប់រងនេះនឹងត្រូវបញ្ចប់ ហើយរាល់សិទ្ធិ និងអត្ថប្រយោជន៍ ដែលមានក្រោមបណ្ណសន្យារ៉ាប់រងនេះនឹងត្រូវបានបញ្ចប់ និងគ្មានប្រសិទ្ធភាពតទៅទៀតនោះទេ។

## XII. ការលុបចោលកិច្ចសន្យាធានារ៉ាប់រង

បណ្ណសន្យារ៉ាប់រងរបស់អ្នកនឹងត្រូវបានលុបចោលដោយស្វ័យប្រវត្តិ នៅពេលករណីណាមួយដូចខាងក្រោមកើតឡើង÷

(១) អ្នកត្រូវបានធានារ៉ាប់រងទទួលមរណភាព ឬពិការភាពទាំងស្រុងនិងជាអចិន្ត្រៃយ៍ ឬការធ្វើរោគវិនិច្ឆ័យរកឃើញជំងឺធ្ងន់ធ្ងរកម្រិតធ្ងន់ ហើយសំណងសម្រាប់មរណភាព ឬពិការភាពទាំងស្រុងនិងជាអចិន្ត្រៃយ៍ ឬជំងឺធ្ងន់ធ្ងរកម្រិតធ្ងន់នោះត្រូវបានទូទាត់រួចរាល់ទាំងស្រុង។

(២) បណ្ណសន្យារ៉ាប់រងនេះដល់កាលកំណត់ ឬផុតកំណត់រយៈពេលនៃការដាក់បន្តសុពលភាពបណ្ណសន្យារ៉ាប់រងឡើងវិញដូចបានចែងនៅក្នុងប្រការ X ឬបណ្ណសន្យារ៉ាប់រងត្រូវបានបញ្ចប់ដូចមានចែងនៅក្នុងប្រការ XI ខាងលើ។

ការទូទាត់ ឬការទទួលយកបុព្វលាភធានារ៉ាប់រងណាមួយបន្ទាប់ពីការលុបចោលបណ្ណសន្យារ៉ាប់រងនេះ នឹងមិនបង្កើតជាទំនួលខុសត្រូវណាមួយមកលើភាគីខាងយើងខ្ញុំឡើយ ប៉ុន្តែយើងខ្ញុំនឹងសងត្រលប់វិញនូវបុព្វលាភធានារ៉ាប់រងដែលបានបង់នោះវិញ។

## XIII. ការទាមទារសំណង

### ១. ការជូនដំណឹងអំពីការទាមទារសំណង

ការជូនដំណឹងភ្លាមៗអំពីការទាមទារសំណងត្រូវប្រគល់ឲ្យយើងខ្ញុំក្នុងរយៈពេល ៩០ (កៅសិប) ថ្ងៃបន្ទាប់ពីថ្ងៃដែលអ្នកត្រូវបានធានារ៉ាប់រងទទួលមរណភាព។ សេចក្តីជូនដំណឹងនឹងត្រូវចាត់ទុកថាបានជូនដំណឹង នៅពេលសេចក្តីជូនដំណឹងនោះត្រូវបានប្រគល់មកឲ្យយើងខ្ញុំនៅការិយាល័យរបស់យើងខ្ញុំដោយភ្ជាប់មកជាមួយនូវព័ត៌មានគ្រប់គ្រាន់សម្រាប់កំណត់អត្តសញ្ញាណអ្នកត្រូវបានធានារ៉ាប់រង។ ប្រសិនបើអ្នកទាមទារសំណងខកខានក្នុងការជូនដំណឹងភ្លាមៗ យើងខ្ញុំនឹងមិនបដិសេធការទាមទារណាមួយឡើយ ប្រសិនបើយើងខ្ញុំត្រូវបានពន្យល់បង្ហាញដោយសមហេតុផលថា អ្នកទាមទារសំណងពុំមានលទ្ធភាពក្នុងការ

ជូនដំណឹងភ្លាមៗតាមរយៈពេលកំណត់ ហើយអ្នកទាមទារសំណងនោះបានព្យាយាមធ្វើការជូនដំណឹងនេះលឿនបំផុតតាមដែលអាចធ្វើបាន។

**២. ភស្តុតាងនៃមរណភាព**

នៅពេលបានទទួលការជូនដំណឹងនេះ យើងខ្ញុំនឹងប្រគល់ជូនអ្នកទាមទារសំណងនូវទម្រង់ពាក្យស្នើសុំសម្រាប់បំពេញដើម្បីជាភស្តុតាងនៃមរណភាព។ ក្នុងករណីទម្រង់ពាក្យស្នើសុំមិនត្រូវបានប្រគល់ទៅឲ្យអ្នកទាមទារសំណងក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃនោះទេ អ្នកទាមទារសំណងអាចចាត់ទុកថាបានអនុវត្តតាមការតម្រូវនៃខ និងលក្ខខណ្ឌនេះ ប្រសិនបើគាត់បានផ្តល់នូវភស្តុតាងជាលាយលក្ខណ៍អក្សររៀបរាប់អំពីព្រឹត្តិការណ៍ និងកាលៈទេសៈនៃការទទួលមរណភាពសម្រាប់សំណងដែលបានទាមទារ។

**៣. ភស្តុតាងនៃពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍**

ភស្តុតាងបង្ហាញអំពីពិការភាពត្រូវដាក់ជូនយើងខ្ញុំ ដែលយើងខ្ញុំជាអ្នកមានសិទ្ធិក្នុងការសម្រេចថាពិការភាពនោះគ្រប់លក្ខខណ្ឌដូចបានកំណត់នៅក្នុងបណ្ណសន្យារ៉ាប់រងនេះ។ យើងខ្ញុំមានសិទ្ធិស្នើឲ្យមានការពិនិត្យអ្នកត្រូវបានធានារ៉ាប់រង និង/ឬ ពិនិត្យលើភស្តុតាងបង្ហាញពីមូលហេតុដែលនាំឲ្យឈានដល់ពិការភាពនោះ ដោយបុគ្គលដែលជ្រើសរើសដោយយើងខ្ញុំ។

**៤. ភស្តុតាងបញ្ជាក់អំពីអាការៈជំងឺធ្ងន់ធ្ងរ**

នៅពេលទទួលបានការជូនដំណឹងនេះ យើងខ្ញុំនឹងប្រគល់ជូនអ្នកទាមទារសំណងនូវទម្រង់ពាក្យស្នើសុំសម្រាប់បំពេញដើម្បីជាភស្តុតាងបញ្ជាក់អំពីអាការៈជំងឺធ្ងន់ធ្ងរ។ ប្រសិនបើទម្រង់ពាក្យស្នើសុំមិនត្រូវបានប្រគល់ឲ្យក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃក្រោយពីទទួលបានលិខិតជូនដំណឹងនេះទេ អ្នកទាមទារសំណងត្រូវបានចាត់ទុកថាបានអនុលោមតាមការតម្រូវនៃ ខ និងលក្ខខណ្ឌនេះ ប្រសិនបើគាត់បានផ្តល់នូវភស្តុតាងជាលាយលក្ខណ៍អក្សរស្តីពីការកើតឡើងនៃអាការៈជំងឺធ្ងន់ធ្ងរ លក្ខណៈ និងកម្រិតនៃអាការៈជំងឺធ្ងន់ធ្ងរដែលបានធ្វើការទាមទារសំណងនោះ។

**៥. ការដាក់ភស្តុតាងបញ្ជាក់អំពីអាការៈជំងឺធ្ងន់ធ្ងរ**

ភស្តុតាងបញ្ជាក់អំពីអាការៈជំងឺធ្ងន់ធ្ងរ ត្រូវប្រគល់ឲ្យយើងខ្ញុំក្នុងអំឡុងពេលរស់រានមានជីវិតរបស់អ្នកត្រូវបានធានារ៉ាប់រង និងក្នុងរយៈពេល ៦ (ប្រាំមួយ) ខែបន្ទាប់ពីការធ្វើរោគវិនិច្ឆ័យនៃអាការៈជំងឺធ្ងន់ធ្ងរនេះ។

### ៦. ការទូទាត់សំណង

បន្ទាប់ពីធ្វើការផ្ទៀងផ្ទាត់ឯកពាក់ព័ន្ធនឹងការទាមទារសំណងរួច ប្រសិនបើត្រូវបានបញ្ជាក់ថាត្រូវធ្វើការទូទាត់សង នោះយើងខ្ញុំនឹងទូទាត់សំណងជូនក្នុងរយៈពេល ៥ (ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីការទាមទារសំណងត្រូវបានអនុម័តដោយយើងខ្ញុំ។

### ៧. របៀបទូទាត់សំណង

ការទូទាត់សំណងអាចត្រូវបានធ្វើឡើងតាមរបៀបផ្សេងៗដូចជា ការផ្ទេរប្រាក់តាមគណនីធនាគារ មូលប្បទានបត្រ សាច់ប្រាក់ និងរបៀបទូទាត់ផ្សេងៗទៀតដែលអាចអនុវត្តបាននៅពេលទូទាត់។

## XIV. ការរក្សាព័ត៌មានសម្ងាត់

រាល់ព័ត៌មានដែលបានផ្តល់ជូនយើងខ្ញុំ នឹងត្រូវរក្សាជាព័ត៌មានសម្ងាត់ ហើយគ្មានព័ត៌មានផ្ទាល់ខ្លួនណាមួយនឹងត្រូវបញ្ចេញទៅឲ្យភាគីទីបីដោយគ្មានការយល់ព្រមជាមុនឡើយ លើកលែងតែបានតម្រូវ ឬអនុញ្ញាតឲ្យដោយច្បាប់ ឬបទប្បញ្ញត្តិជាធរមាន។

## XV. ការដោះស្រាយវិវាទ និងដែនយុត្តាធិការ

បណ្ណសន្យារ៉ាប់រងនេះត្រូវបានគ្រប់គ្រងដោយច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។ ប្រសិនបើជម្លោះណាមួយកើតចេញពី ឬពាក់ព័ន្ធនឹងបណ្ណសន្យារ៉ាប់រងនេះមិនអាចដោះស្រាយតាមរយៈការចរចាដោយសន្តិវិធីដែលជាជម្រើសដំបូងរវាងក្រុមហ៊ុន និងម្ចាស់បណ្ណសន្យារ៉ាប់រង គូភាគីយល់ព្រមដោយសុចរិតក្នុងការដោះស្រាយជម្លោះនេះតាមរយៈការសម្របសម្រួលពីនិយ័តករធានារ៉ាប់រងកម្ពុជា មុននឹងបញ្ជូនទៅតុលាការនៃព្រះរាជាណាចក្រកម្ពុជាដែលមានសមត្ថកិច្ចផ្តាច់មុខ។

## XVI. បទប្បញ្ញត្តិទូទៅ

### ១. បណ្ណសន្យារ៉ាប់រង

បណ្ណសន្យារ៉ាប់រងនេះត្រូវបានផ្តល់ជូនជាតម្លៃតបស្នងទៅនឹងការបង់បុព្វលាភធានារ៉ាប់រង ដូចបានកំណត់ក្នុងវិញ្ញាបនបត្រធានារ៉ាប់រង និងអនុលោមតាម÷

(១) ចម្លើយដែលបានផ្តល់ដោយអ្នក និង/ ឬ អ្នកត្រូវបានធានារ៉ាប់រង ក្នុងទម្រង់ពាក្យស្នើសុំ ឬទម្រង់សំណើសុំរបស់អ្នក ឬកម្រងសំណួរដែលយើងខ្ញុំផ្តល់នៅពេលក្រោយៗពាក់ព័ន្ធនឹងសំណើ

របស់អ្នក និងព័ត៌មានណាមួយដែលផ្តល់ដោយអ្នក ក្នុងចន្លោះពេលរវាងការដាក់ពាក្យស្នើសុំ ឬសំណើ និងពេលដែលកិច្ចសន្យានេះត្រូវបានបង្កើតឡើង និង

(២) របាយការណ៍សុខភាព និងរបាយការណ៍ផ្សេងៗ ព្រមទាំងកម្រងសំណួរផ្សេងៗទៀត (ដែលហៅរួមគ្នាថា“ឯកសារព័ត៌មាន”)ហើយឯកសារព័ត៌មាននេះត្រូវក្លាយជាផ្នែកមួយនៃកិច្ចសន្យាធានារ៉ាប់រងរវាងយើងខ្ញុំ និងអ្នក។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ក្នុងករណីមានការផ្តល់ព័ត៌មានមិនពិតណាមួយនៅមុនពេលចុះកិច្ចសន្យាពាក់ព័ន្ធនឹង ឯកសារព័ត៌មាននេះមានតែសំណងដែលផ្តល់ជូនតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជាប៉ុណ្ណោះដែលនឹងត្រូវបានយកមកអនុវត្ត។

បណ្ណសន្យារ៉ាប់រងរបស់អ្នក រួមមានបណ្ណសន្យារ៉ាប់រងផលិតផលមូលដ្ឋាន និងអត្ថប្រយោជន៍ធានារ៉ាប់រងបន្ថែមដែលអាចនឹងត្រូវបានភ្ជាប់ជាមួយ។ ឈ្មោះផលិតផលនៃបណ្ណសន្យារ៉ាប់រងផលិតផលមូលដ្ឋាន និង/ ឬឈ្មោះកូដ និង/ ឬឈ្មោះផលិតផល និងលេខទម្រង់នៃអត្ថប្រយោជន៍ធានារ៉ាប់រងបន្ថែម ប្រសិនបើមានភ្ជាប់មកជាមួយបណ្ណសន្យារ៉ាប់រងនេះ នឹងត្រូវបានបង្ហាញនៅក្នុងតារាងអត្ថប្រយោជន៍ និងបុព្វលាភធានារ៉ាប់រងនៃវិញ្ញាបនបត្រធានារ៉ាប់រង។

### ២. រូបិយបណ្ណ និងរបៀបបង់ប្រាក់

រាល់ទឹកប្រាក់ដែលត្រូវបង់ឲ្យយើងខ្ញុំ ឬដោយយើងខ្ញុំ ត្រូវជារូបិយបណ្ណដែលមានបង្ហាញលើវិញ្ញាបនបត្រធានារ៉ាប់រង ឬការព្រមព្រៀងបន្តបន្ទាប់ទៀត។ រាល់ទឹកប្រាក់ដែលយើងខ្ញុំត្រូវបង់ ត្រូវធ្វើឡើងតាមរបៀបដែលកំណត់ដោយយើងខ្ញុំ។

### ៣. បទប្បញ្ញត្តិលើទិន្នន័យដែលតម្រូវ

(១) រាល់ព័ត៌មានផ្ទាល់ខ្លួនដែលយើងខ្ញុំបានប្រមូល ឬកាន់កាប់ដែលទាក់ទងនឹងអ្នកត្រូវបានធានារ៉ាប់រងម្នាក់ៗ ក្រោមបណ្ណសន្យារ៉ាប់រងនេះ អាចនឹងត្រូវបានប្រើប្រាស់ និងបង្ហាញដោយយើងខ្ញុំចំពោះបុគ្គល ឬអង្គការដែលពាក់ព័ន្ធជាមួយយើងខ្ញុំសម្រាប់បញ្ហាដែលទាក់ទងនឹងការធានារ៉ាប់រងរបស់អ្នកត្រូវបានធានារ៉ាប់រង។

(២) វាគឺជាទំនួលខុសត្រូវរបស់អ្នក ក្នុងការធានាថាព័ត៌មានផ្ទាល់ខ្លួនដែលបានផ្តល់ជូនយើងខ្ញុំត្រូវមានភាពត្រឹមត្រូវច្បាស់លាស់។ អ្នកត្រូវទទួលខុសត្រូវសងសំណង និងបន្តទទួលខុសត្រូវសងសំណងមកយើងខ្ញុំ ចំពោះរាល់ការខាតបង់ថ្លៃសេវា ការចំណាយ សកម្មភាពនានាដែលយើងខ្ញុំបានទទួលរងគ្រោះដែលជាលទ្ធផលនៃការថ្លោះធ្លោយរបស់អ្នកក្នុងការអនុវត្តតាមខ និងលក្ខខណ្ឌខាងលើ។

## ៤. តម្លៃសាច់ប្រាក់នៃបណ្ណសន្យារ៉ាប់រង

បន្ទាប់ពីបុព្វលាភធានារ៉ាប់រងរយៈពេល ២ (ពីរ) ឆ្នាំត្រូវបានបង់រួច ហើយបណ្ណសន្យារ៉ាប់រងនេះមានសុពលភាពគ្រប់រយៈពេល ២ (ពីរ) ឆ្នាំ អ្នកអាចស្នើសុំបញ្ចប់បណ្ណសន្យារ៉ាប់រងនេះជាលាយលក្ខណ៍អក្សរមកកាន់យើងខ្ញុំតាមទម្រង់ដែលយើងខ្ញុំបានកំណត់ដើម្បីទទួលបានតម្លៃសាច់ប្រាក់ ដូចមានចែងនៅក្នុងវិញ្ញាបនបត្រធានារ៉ាប់រងដោយដកចេញនូវចំនួនទឹកប្រាក់ដែលបានជំពាក់នានា។ បន្ទាប់ពីយើងខ្ញុំបានផ្តល់នូវតម្លៃសាច់ប្រាក់ជូនអ្នករួចរាល់ បណ្ណសន្យារ៉ាប់រងនេះត្រូវបញ្ចប់ ហើយរាល់អត្ថប្រយោជន៍ និងសិទ្ធិដែលស្របតាមបណ្ណសន្យារ៉ាប់រងនេះក៏ត្រូវបានបញ្ចប់ដែរ។ ប៉ុន្តែ ប្រសិនបើអ្នកស្នើសុំបញ្ចប់បណ្ណសន្យារ៉ាប់រងនេះបន្ទាប់ពីផុតរយៈពេលសម្រេចចិត្ត និងមុនពេលបណ្ណសន្យារ៉ាប់រងនេះមានសុពលភាពគ្រប់រយៈពេល ២ (ពីរ) ឆ្នាំ អ្នកនឹងពុំទទួលបានតម្លៃសាច់ប្រាក់នោះទេ ហើយបណ្ណសន្យារ៉ាប់រងនេះត្រូវបញ្ចប់ រួមទាំងសិទ្ធិ និងអត្ថប្រយោជន៍ដែលស្របតាមបណ្ណសន្យារ៉ាប់រងនេះក៏ត្រូវបានបញ្ចប់ដែរ។

## ៥. ការផ្តល់ព័ត៌មានមិនពិតអំពីអាយុ និង/ឬភេទ

(១) អាយុដែលមានបង្ហាញនៅក្នុងវិញ្ញាបនបត្រធានារ៉ាប់រងគឺជាអាយុរបស់អ្នកត្រូវបានធានារ៉ាប់រងដែលបានប្រកាសក្នុងពាក្យស្នើសុំធានារ៉ាប់រងរបស់អ្នក។ អាយុដែលបានលើកឡើងខាងដើមនេះ គឺសំដៅអាយុគិតត្រឹមថ្ងៃកំណើតចុងក្រោយរបស់អ្នកត្រូវបានធានារ៉ាប់រងនៅកាលបរិច្ឆេទចាប់ផ្តើមសុពលភាពនៃបណ្ណសន្យារ៉ាប់រង។

ក្នុងករណីមានការផ្តល់ព័ត៌មានមិនពិតអំពីអាយុ និង/ឬ ភេទ បុព្វលាភធានារ៉ាប់រង និង/ឬ អត្ថប្រយោជន៍ដែលត្រូវបង់ នឹងត្រូវកែសម្រួលដោយយោងទៅតាមអាយុ និង/ឬ ភេទពិតប្រាកដរបស់អ្នកត្រូវបានធានារ៉ាប់រង។

ក្នុងកំឡុងពេល ២ (ពីរ) ឆ្នាំដំបូងនៃបណ្ណសន្យារ៉ាប់រងនេះ ប្រសិនបើយើងរកឃើញថានៅថ្ងៃដាក់ពាក្យស្នើសុំ អាយុពិតរបស់អ្នកត្រូវបានធានារ៉ាប់រងបែរជាមានអាយុច្រើនជាង ឬតិចជាងអាយុដាក់ពាក្យស្នើសុំដែលបានកំណត់ យើងមានសិទ្ធិលុបចោលនូវបណ្ណសន្យារ៉ាប់រងនេះ និងផ្តល់ត្រឡប់នូវ បុព្វលាភដែលអ្នកបានបង់ត្រលប់ទៅវិញ។

(២) ប្រសិនបើអ្នកត្រូវបានធានារ៉ាប់រងមិនមានសិទ្ធិក្នុងការទទួលបានការធានារ៉ាប់រងទៅតាមអាយុ និង/ឬ ភេទពិតប្រាកដ បណ្ណសន្យារ៉ាប់រងនេះនឹងត្រូវចាត់ទុកជាមោឃៈ ហើយយើងខ្ញុំនឹងបង្វិលសងជូនអ្នកវិញនូវបុព្វលាភដែលបានបង់។

(៣) ការបង់ជូននូវអត្ថប្រយោជន៍ស្របតាមបណ្ណសន្យារ៉ាប់រងនេះនឹងត្រូវបានធ្វើឡើង តែក្នុងករណីអាយុ និង/ឬ ភេទរបស់អ្នកត្រូវបានធានារ៉ាប់រង ត្រូវបានផ្ទៀងផ្ទាត់ និងបញ្ជាក់ថាត្រឹមត្រូវ។ អាយុ និង/ឬ ភេទរបស់អ្នកត្រូវបានធានារ៉ាប់រងនឹងត្រូវបានផ្ទៀងផ្ទាត់ និងបញ្ជាក់ថាត្រឹមត្រូវ ប្រសិនបើមានភស្តុតាងជាក់លាក់ប្រគល់មកឱ្យយើងខ្ញុំ។

### ៦. ភាពមិនអាចជំទាស់បាន

ការខកខានរបស់ម្ចាស់បណ្ណសន្យារ៉ាប់រង ឬអ្នកត្រូវបានធានារ៉ាប់រងក្នុងការប្រកាសបង្ហាញពីចំណុចណាមួយ ឬការថ្លែងមិនពិតរបស់ពួកគេពីចំណុចណាមួយដែលខ្លួនបានយល់ដឹងថាជាចំណុចសំខាន់សម្រាប់ការធានារ៉ាប់រង (ហើយដែលមិនបានប្រកាសបង្ហាញមកយើងខ្ញុំដោយភាគីណាផ្សេងទៀត) តែមិនមានលក្ខណៈជាការបន្លំ នោះមិនអាចជាមូលហេតុនាំឱ្យក្រុមហ៊ុនចាត់ទុកបណ្ណសន្យារ៉ាប់រងនេះជាមោឃៈបានទេ បន្ទាប់ពីបណ្ណសន្យារ៉ាប់រងនេះបានមានសុពលភាពអស់រយៈពេល ២ ឆ្នាំ រាប់ចាប់ពីកាលបរិច្ឆេទចាប់ផ្តើមសុពលភាព ឬកាលបរិច្ឆេទចាប់ផ្តើម ដោយយកកាលបរិច្ឆេទណាមួយចុងក្រោយគេបង្អស់។

ការខកខានក្នុងការប្រកាសបង្ហាញ ឬ ការថ្លែងមិនពិតអាចកើតមានឡើងលើពាក្យស្នើសុំធានារ៉ាប់រង ទម្រង់បែបបទភស្តុតាងពិនិត្យសុខភាព ឬ របាយការណ៍ និងចម្លើយជាលាយលក្ខណ៍អក្សរណាមួយ ដែលជាភស្តុតាងនៃភាពអាចធានារ៉ាប់រងបាន។

## XVII. ខ និងលក្ខខណ្ឌស្តីពីភាពជាម្ចាស់បណ្ណសន្យារ៉ាប់រង

### ១. ម្ចាស់បណ្ណសន្យារ៉ាប់រង

អ្នកជាម្ចាស់នៃបណ្ណសន្យារ៉ាប់រងនេះ ដូចដែលមានបង្ហាញក្នុងវិញ្ញាបនបត្រធានារ៉ាប់រង រហូតដល់មានការផ្លាស់ប្តូរផ្សេងពីនេះ។ ក្នុងអំឡុងពេលអ្នកត្រូវបានធានារ៉ាប់រងនៅរស់រានមានជីវិត ក្នុងនាមជាម្ចាស់បណ្ណសន្យារ៉ាប់រង មានតែអ្នកប៉ុណ្ណោះដែលមានសិទ្ធិអនុវត្តរាល់សិទ្ធិ ឯកសិទ្ធិ និងជម្រើសដែលផ្តល់ជូន ក្រោមបណ្ណសន្យារ៉ាប់រងនេះ ដោយអនុលោមតាមការយល់ព្រមជាលាយលក្ខណ៍អក្សររបស់អ្នក និងនៅក្នុងកម្រិត

សិទ្ធិរបស់អ្នកទទួលសិទ្ធិ (អនុប្បទានិក) ប្រសិនបើមាន។ ពេលអ្នកទទួលមរណភាព សិទ្ធិ ឯកសិទ្ធិ និង ជម្រើសទាំងនេះត្រូវផ្ទេរឱ្យម្ចាស់បណ្ណសន្យារ៉ាប់រងបម្រុង តាមករណីជាក់ស្តែង។

**២.ការផ្លាស់ប្តូរម្ចាស់បណ្ណសន្យារ៉ាប់រង និងការគ្រប់គ្រងសិទ្ធិ**

ក្នុងអំឡុងពេលបណ្ណសន្យារ៉ាប់រងនេះមានសុពលភាព អ្នកអាចផ្លាស់ប្តូរម្ចាស់បណ្ណសន្យារ៉ាប់រងនេះ និង/ឬអ្នកទទួលផលដោយដាក់ជូននូវសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរ។ ការផ្លាស់ប្តូរនេះមានសុពលភាព ប្រសិនបើត្រូវបានកត់ត្រាទុកដោយយើងខ្ញុំក្នុងអំឡុងពេលអ្នកត្រូវបានធានារ៉ាប់រងរស់រានមានជីវិត និងត្រូវបានយល់ព្រមលើបណ្ណសន្យារ៉ាប់រងតែប៉ុណ្ណោះ។ យើងខ្ញុំនឹងមិនទទួលខុសត្រូវលើសុពលភាពនៃការផ្លាស់ប្តូរការគ្រប់គ្រងសិទ្ធិណាមួយឡើយ។

រាល់ការផ្លាស់ប្តូរការគ្រប់គ្រងសិទ្ធិទាំងអស់ត្រូវធ្វើឡើង ដោយអាស្រ័យលើស្ថានភាពបំណុលដែលកើតមានក្រោមបណ្ណសន្យារ៉ាប់រងនេះ។

## XVIII. ខ និងលក្ខខណ្ឌផ្សេងៗទៀត

(១) ការបំពានលើច្បាប់ ការអស់សុពលភាព ឬភាពមិនអាចអនុវត្តបាននៃប្រការណាមួយក្នុងខ និងលក្ខខណ្ឌទូទៅក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា នឹងមិនត្រូវប៉ះពាល់ដល់ប្រសិទ្ធិភាពនៃច្បាប់ ឬភាពដែលអាចអនុវត្តបាននៃខ និងលក្ខខណ្ឌផ្សេងទៀតក្នុងបណ្ណសន្យារ៉ាប់រងនេះឡើយ។

(២) បញ្ជីឯកសារ និង/ឬ គណនីរបស់យើងខ្ញុំគឺជាភស្តុតាងចុងក្រោយអំពីស្ថានភាពគណនីរវាងគូភាគីក្នុង បណ្ណសន្យារ៉ាប់រងនេះ។ ការបញ្ជាក់ណាមួយរបស់បុគ្គលិកយើងខ្ញុំពាក់ព័ន្ធនឹងទឹកប្រាក់ ឬការទទួលខុសត្រូវនាពេលបច្ចុប្បន្នដែលមិនទាន់បានបង់ ឬនៅសល់ ដែលយើងខ្ញុំបានចំណាយសម្រាប់អ្នកត្រូវបានធានារ៉ាប់រង ត្រូវជាប់ជាកាតព្វកិច្ច និងចាត់ទុកជាភស្តុតាងសំខាន់ និងចុងក្រោយសម្រាប់អ្នកត្រូវបានធានារ៉ាប់រង ក្នុងតុលាការគ្រប់ជាន់ថ្នាក់ និងស្ថាប័នមានសមត្ថកិច្ចផ្សេងទៀត។

(៣) ប្រសិនបើយើងខ្ញុំពន្យារពេល ឬខកខានក្នុងការអនុវត្តសិទ្ធិ ឬដំណោះស្រាយតាមផ្លូវច្បាប់ណាមួយក្រោមបណ្ណសន្យារ៉ាប់រងនេះ នឹងមិនត្រូវចាត់ទុកជាការបោះបង់ចោលឡើយ។ ការអនុវត្តសិទ្ធិ ឬដំណោះស្រាយផ្លូវច្បាប់តែមួយ ឬដោយផ្នែក មិនអាចរារាំងយើងខ្ញុំពីការអនុវត្តសិទ្ធិ ឬដំណោះស្រាយតាមផ្លូវច្បាប់ណាផ្សេងទៀតបានឡើយ។ សិទ្ធិ ឬដំណោះស្រាយតាមផ្លូវច្បាប់ផ្តល់ឲ្យក្នុងបណ្ណសន្យារ៉ាប់រងនេះ

ត្រូវបូកបន្ថែម និងរាប់បញ្ចូលទាំងសិទ្ធិ ឬដំណោះស្រាយតាមផ្លូវច្បាប់ផ្សេងទៀត (មិនថាផ្តល់ឲ្យដោយច្បាប់ ឬផ្សេងពីនេះ)។

(៤) បណ្ណសន្យារ៉ាប់រងនេះត្រូវបន្តមានសុពលភាព និងចងភ្ជាប់ជាកាតព្វកិច្ចសម្រាប់រាល់គោលបំណងទាំងអស់ ទោះមានការផ្លាស់ប្តូរណាមួយដូចជាការរំលាយបញ្ចូលគ្នា ការផ្លាស់ប្តូរឈ្មោះ ការស្ថាបនាឡើងវិញ ឬផ្សេងពីនេះ ដែលអាចនឹងត្រូវបានធ្វើឡើងក្រោមការកំណត់របស់យើងខ្ញុំ។

(៥) ខ និងលក្ខខណ្ឌដែលបានចែងក្នុងបណ្ណសន្យារ៉ាប់រងនេះបង្កើតបានជាខ និងលក្ខខណ្ឌទាំងមូលរបស់បណ្ណសន្យារ៉ាប់រងនេះ។ មិនមានការធានារ៉ាប់រងអះអាង ឬការរាយការណ៍ផ្ទុយពីនេះពីមុនណាមួយធ្វើឡើងពាក់ព័ន្ធនឹងបណ្ណសន្យារ៉ាប់រង ទោះដោយផ្ទាល់មាត់ ឬដោយលាយលក្ខណ៍អក្សរ ត្រូវបានចាត់ទុកជាផ្នែកនៃបណ្ណសន្យារ៉ាប់រងនេះឡើយ។

(៦) យើងខ្ញុំរក្សាសិទ្ធិក្នុងការកែប្រែខ និងលក្ខខណ្ឌនៃបណ្ណសន្យារ៉ាប់រងនេះ តាមវិធីនិងហេតុផលដែលយើងខ្ញុំគិតថាសមស្រប ក្នុងករណីមានការផ្លាស់ប្តូរណាមួយក្នុងច្បាប់ ឬតាមគោលការណ៍នៃការប្រមូលពន្ធដែលត្រូវអនុវត្តចំពោះយើងខ្ញុំ ឬចំពោះបណ្ណសន្យារ៉ាប់រងនេះ។

## XIX. តារាងជំងឺធ្ងន់ធ្ងរ

### ១. និយមន័យនៃជំងឺធ្ងន់ធ្ងរកម្រិតដំបូង

| | |
|---|---|
| **១. ជាលិកាមហារីកនៅទីតាំងដើម (ស៊ីអាយអេស) នៃសរីរាង្គស្ត្រី** | ជាលិកាមហារីកនៅទីតាំងដើម (ស៊ីអាយអេស) មានន័យថាការលូតលាស់ថ្មីដោយស្វ័យភាព នៅត្រង់ចំណុចកណ្តាលនៃកោសិកាមហារីកដែលព័ទ្ធដោយកោសិកាដែលវាស្ថិតនៅក្នុង និងមិនទាន់មានការរាតត្បាត/រាលដាល និង/ ឬ បំផ្លាញជាលិកានៅជុំវិញ។ ការរាតត្បាត/រាលដាលមានន័យថាការជ្រៀតចូល និង/ ឬ ការបំផ្លាញយ៉ាងសកម្មលើជាលិកាធម្មតាហួសពីភ្នាសគ្រឹះនៃជាលិកា។ ជាលិកាមហារីកនៅទីតាំងដើមលើសរីរាង្គស្ត្រីត្រូវបានធានាមានដូចជា÷ សុដន់ មាត់ស្បូន ស្បូនក្រពេញអូវែរ បំពង់ដៃស្បូន ឬទ្វារមាស ឬប្រដាប់បន្តពូជស្ត្រីផ្នែកខាងក្រៅ។ |

| | |
|---|---|
| | ការធ្វើរោគវិនិច្ឆ័យជាលិកាមហារីកនៅទីតាំងដើម (ស៊ីអាយអេស) ត្រូវតែមានការអះអាងដោយរបាយការណ៍ជាលិកាសាស្ត្រជានិច្ច។ លើសពីនេះទៀត ការធ្វើរោគវិនិច្ឆ័យជាជាលិកាមហារីកនៅទីតាំងដើមត្រូវពិនិត្យឃើញវិជ្ជមានជានិច្ចតាមរយៈមូលដ្ឋាននៃការពិនិត្យដោយមីក្រូទស្សន៍លើជាលិកាជាក់លាក់ ដែលអះអាងដោយលទ្ធផលពីការកាត់ច្រឹបយកជាលិកាដើម្បីធ្វើរោគវិនិច្ឆ័យ។ ការធ្វើរោគវិនិច្ឆ័យតាមរយៈសញ្ញាគ្លីនិកមិនអាចបំពេញបទដ្ឋាននេះទេ។<br><br>ក្នុងករណីជំងឺមហារីកមាត់ស្បូន ការកៀរយករំអិលមាត់ស្បូនយកទៅមន្ទីរពិសោធន៍ ដើម្បីពិនិត្យមើលពីការប្រែប្រួលនៃកោសិកា (តេស្តផេបស្មៀរ) តែមួយមុខមិនអាចយកជាការបានទេ ដោយតម្រូវឲ្យធ្វើជាមួយនឹងការកាត់ច្រឹបយកជាលិកាមាត់ស្បូន (ខូនបាយអប់ស៊ី) ទៅពិនិត្យ ឬតាមរយៈការប្រើឧបករណ៍ឆ្លុះតាមទ្វារមាសដើម្បីពិនិត្យមើលជាលិកាមាត់ស្បូន (កុលប៉ូស្កូពី) ដើម្បីច្រឹបយកសាច់មាត់ស្បូនទៅវិភាគថែមទៀតផង។ ការធ្វើរោគវិនិច្ឆ័យតាមសញ្ញាគ្លីនិក ឬការបែងចែកដំណាក់កាលត្រៀមកើតមហារីកមាត់ស្បូន (ស៊ីអាយអិន) ដែលបង្ហាញពីដំណាក់កាលត្រៀមមធ្យម (ស៊ីអាយអិន I) ដំណាក់កាលត្រៀមធ្ងន់ (ស៊ីអាយអិន II) និងដំណាក់កាលត្រៀមធ្ងន់ធ្ងរខ្លាំង (ស៊ីអាយអិន III) (ការវិវឌ្ឍន៍ត្រៀមកើតមហារីកធ្ងន់ធ្ងរដោយគ្មានជាលិកាមហារីកនៅទីតាំងដើម) មិនបំពេញបានគ្រប់គ្រាន់តាមនិយមន័យដែលបានតម្រូវ និងត្រូវជាករណីលើកលែងជាពិសេស។<br><br>ជាលិកាមហារីកនៅទីតាំងដើម(ស៊ីអាយអេស)នៃក្រពេញអូវែរ ត្រូវមានស្រោមព័ទ្ធជុំវិញ ដោយមិនមានដុំសាច់នៅលើផ្ទៃរបស់ក្រពេញអូវែរនោះ ហើយត្រូវបានធ្វើចំណាត់ថ្នាក់តាមរយៈជាលិកាសាស្ត្រធីអិនអឹមជាធី១អេ អិន០ អឹម០ (ចំណាត់ថ្នាក់នៃជាលិកាមហារីកតាមវិធីសាស្ត្រ ធីអិនអឹម) ឬសហព័ន្ធអន្តរជាតិរោគស្ត្រីនិងសម្ភពកម្រិតមួយអេ (ហ្វាយហ្គោ១អេ)។ ជា |

| | |
|---|---|
| | លិកាមហារីកនៅទីតាំងដើមស្ថិតនៅលើទ្វារមាសគួរតែត្រូវបានធ្វើចំណាត់ថ្នាក់ដោយយោងតាមវិធីសាស្ត្រធីអិនអឹមជា ធីអាយអេស ឬតាមរយៈសហព័ន្ធអន្តរជាតិរោគស្ត្រីនិងសម្ភពកម្រិតសូន្យ (ហ្វាយហ្គោ 0) ។<br><br>ការធានារ៉ាប់រងនេះមានតែលើការកើតឡើងលើកទីមួយនៃជាលិកាមហារីកនៅទីតាំងដើមតែប៉ុណ្ណោះ។ ជាលិកាមហារីកនៅទីតាំងដើមដែលកើតឡើងចំពោះបុគ្គលដែលមានប្រព័ន្ធភាពស៊ាំចុះខ្សោយ ដែលបង្កដោយជំងឺអេដស៍ មិនត្រូវបានរាប់បញ្ចូលនោះទេ។ |

## ២. និយមន័យនៃជំងឺធ្ងន់ធ្ងរកម្រិតធ្ងន់

| | |
|---|---|
| **២. ជំងឺមហារីកលើសរីរាង្គស្ត្រី និងកម្រិតធ្ងន់ធ្ងរជាក់លាក់ (មិនរាប់បញ្ចូលនូវមហារីកដំណាក់កាលដំបូងឡើយ)** | ជំងឺមហារីកត្រូវបានកំណត់ជានិយមន័យ ថាជាដុំសាច់កាចសាហាវដែលត្រូវបានកំណត់រោគវិនិច្ឆ័យវិជ្ជមានតាមរយៈការវិភាគរោគវិទ្យា ហើយបញ្ជាក់លក្ខណៈដោយមានការលូតលាស់មិនប្រក្រតីនៃកោសិកាកាចសាហាវ និងប៉ះពាល់ដល់ជាលិកាផ្សេងទៀតដែលចាំបាច់ទាមទារអោយមានការព្យាបាល ឬធ្វើការវះកាត់ (មិនរាប់បញ្ចូលការវះកាត់ដោយប្រើឧបករណ៍ អង់ដូស្កុប)។<br><br>ជំងឺមហារីកដែលត្រូវបានធានារ៉ាប់រង នៅក្នុងកិច្ចសន្យានេះមានដូចជា÷<br>មហារីកសុដន់ មហារីកមាត់ស្បូន មហារីកស្បូន មហារីកក្រពេញអូវែរ មហារីកបំពង់ដៃស្បូន ឬមហារីកទ្វារមាសឬប្រដាប់បន្តពូជស្ត្រីផ្នែកខាងក្រៅ។<br><br>យោងតាមនិយមន័យខាងលើ លក្ខខណ្ឌដែលមិនត្រូវបានធានារ៉ាប់រងមានដូចជា÷ |

| | |
|---|---|
| | (i) ជំងឺមហារីកទាំងឡាយណាដែលត្រូវបានធ្វើចំណាត់ថ្នាក់តាមរយៈរោគវិទ្យាមានដូចជា÷<br>- បម្រុងមហារីក<br>- ដែលមិនមានការរាតត្បាតទៅសរីរាង្គផ្សេង<br>- នៅទីតាំងដើម<br>- ដែលស្រដៀងនឹងជំងឺមហារីកកាចសាហាវ<br>- ដែលមានសក្តានុពលអាចក្លាយជាកាចសាហាវ<br>(ii) ជំងឺមហារីកទាំងឡាយណាដែលកើតលើបុគ្គលដែលផ្ទុកមេរោគអេដស៍ (វីរុសហ៊ីវ)<br>(iii) ជំងឺមហារីកដែលកើតចេញពីសរីរាង្គ ឬជាលិកាផ្សេងទៀតនៃសារពាង្គកាយហើយរាតត្បាតឬប៉ះពាល់ដល់សរីរាង្គបន្តពូជស្ត្រី ឬសុដន់។ |